ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ផែនការមេ

ស្តីពី

បរិវត្តកម្មព្រឹទ្ធសភាអេឡិចត្រូនិក
២០២២-២០៣០

បច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់ទាំងអស់គ្នា



អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
(ខែកុម្ភៈ ឆ្នាំ២០២២)

មាតិកា
ផែនការមេបរិវត្តកម្មព្រឹទ្ធសភាអេឡិចត្រូនិក
(២០២២-២០៣០)

I-សេចក្តីផ្តើម..០១
II-ទស្សនទាននៃសភាអេឡិចត្រូនិក..០២
១-និយមន័យ..០២
២-បច្ច័យវិជ្ជមាននៃសភាអេឡិចត្រូនិក..០៤
III-បច្ចេកវិទ្យាព័ត៌មាន និងមុខងារព្រឹទ្ធសភា..០៥
១-បច្ចេកវិទ្យាព័ត៌មាន និងមុខងារនីតិកម្ម..០៥
២-បច្ចេកវិទ្យាព័ត៌មាន និងមុខងារតាមដានការអនុវត្តច្បាប់..០៦
៣-បច្ចេកវិទ្យាព័ត៌មាន និងមុខងារតំណាង..០៧
IV-សេវាសភាអេឡិចត្រូនិក..០៨
V-វឌ្ឍនភាពបច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភា..០៩
១-បច្ចុប្បន្នភាពអគ្គលេខាធិការដ្ឋាន..០៩
២-ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា..១០
៣-ឧបករណ៍អេឡិចត្រូនិក..១១
៤-សេវាកម្ម និងសុហ្វែរព័ត៌មានវិទ្យា..១១
៥-កត្តាអំណោយផល និងការប្រឈម..១១
VI-ផែនការមេបរិវត្តកម្មព្រឹទ្ធសភាអេឡិចត្រូនិក..១៣
១-ទស្សនវិស័យ..១៣
២-បេសកកម្ម..១៤
៣-គោលបំណង..១៤
៤-សារៈសំខាន់នៃផែនការមេ..១៤
៥-គោលដៅជាអាទិភាព..១៥
- គោលដៅអាទិភាពទី១ ....១៥
(ពង្រឹងពង្រីកហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាប្រកបដោយភាពរឹងមាំ និងមានលក្ខណៈជាប្រព័ន្ធពពក (CLOUD))
- គោលដៅអាទិភាពទី២..១៧
(ពង្រឹងពង្រីកផលិតភាពការងារ និងសេវាកម្មបច្ចេកវិទ្យាព័ត៌មាន ដើម្បីគាំទ្រមុខងារស្នូលទាំងបីរបស់ព្រឹទ្ធសភាប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈវៃឆ្លាត)

- គោលដៅអាទិភាពទី៣ .... ១៩
(ការពង្រីកការគ្រប់គ្រង និងការទទួលយកគម្រោងបច្ចេកវិទ្យាព័ត៌មានសម្រាប់ព្រឹទ្ធសភា)
- គោលដៅអាទិភាពទី៤ .... ២០
(ពង្រឹងពង្រីកទំនាក់ទំនងសាធារណៈ និងព័ត៌មានដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន)
- គោលដៅអាទិភាពទី៥ .... ២១
(ការកសាង និងអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្សប្រកបដោយលក្ខណៈឈ្លាសវៃ)
- គោលដៅអាទិភាពទី៦ .... ២២
(ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការ-ភាពជាដៃគូជាមួយនឹងដៃគូពាក់ព័ន្ធដើម្បីពង្រឹងពង្រីកការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភា)
VII-**យន្តការដឹកនាំ សម្របសម្រួល និងអនុវត្តន៍ផែនការមេ** ២៣
១-យន្តការស្ថាប័នសម្រាប់សម្របសម្រួល និងអនុវត្តន៍ ២៣
ក.គណៈកម្មការបច្ចេកវិទ្យាព័ត៌មានព្រឹទ្ធសភា ២៣
ខ.ក្រុមការងារបច្ចេកទេសពិសេស ២៤
គ.មជ្ឈមណ្ឌលព័ត៌មានវិទ្យាព្រឹទ្ធសភា ២៤
ឃ.កិច្ចសហប្រតិបត្តិការជាតិ-អន្តរជាតិ ២៤
២-ការវាយតម្លៃ និងការតាមដានការអនុវត្តផែនការមេ ២៥
ក.ការតាមដាន ២៥
ខ.ការវាយតម្លៃ ២៦
៣-ឱកាស និងបញ្ហាប្រឈម ២៦
៤-លទ្ធផលរំពឹងទុក ២៧
៥-ទីតាំង(Focus Area) ២៧
៦-អតិថិជនគោលដៅ (Target Audiences) ២៨
៧-បណ្តាញ និងផលិតផល ២៨
៨-ធនធានមនុស្ស និងហិរញ្ញវត្ថុ ២៨
VIII-**ការគ្រប់គ្រងហានិភ័យ** ៣០
១-ហានិភ័យរបៀបរបបការងារសភា ៣០
២-ហានិភ័យនៃការប្រើប្រាស់អ្នកផ្គត់ផ្គង់ខាងក្រៅ ៣០
៣-ហានិភ័យពាក់ព័ន្ធនឹងធនធានមនុស្ស និងហិរញ្ញវត្ថុ ៣១
៤-ហានិភ័យពាក់ព័ន្ធនឹងការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាព័ត៌មាន ៣១
៥-ហានិភ័យពាក់ព័ន្ធនឹងសន្តិសុខបច្ចេកវិទ្យាព័ត៌មាន ៣២
៦-ហានិភ័យពាក់ព័ន្ធនឹងប្រធានសក្តិ ៣២

IX-**សេចក្តីសន្និដ្ឋាន**..៣៣
X-**សន្ទានុក្រម**...៣៨
XI-**ឧបសម្ព័ន្ធ**...៤៤

ឲឲ★ៜៜ

I-សេចក្តីផ្តើម

ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានចាប់បដិសន្ធិនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ ហើយនីតិកាលកន្លងទៅ ព្រឹទ្ធសភាបានខិតខំប្រឹងប្រែងជាមួយនឹងរដ្ឋសភាក្នុងនាមជាស្ថាប័ននីតិប្បញ្ញត្តិក្នុងការបំពេញការងាររបស់ខ្លួន ទទួលបាននូវសមិទ្ធផលជូនសង្គមជាតិគួរឱ្យកត់សម្គាល់។ នៅក្នុងពីរទសវត្សរ៍ចុងក្រោយនេះ សង្គមជាតិកម្ពុជាបានវិវឌ្ឍន៍ទៅមុខជាមួយនឹងវឌ្ឍនភាពសង្គម និងសេដ្ឋកិច្ច ប្រកបដោយភាពរីកចម្រើន និងធំធាត់ជាលំដាប់ក្រោមដំបូលសន្តិភាព និងការអភិវឌ្ឍ។ វឌ្ឍនភាពនេះជាកត្តាសត្យានុម័ត និងអត្តនោម័តដែលជំរុញឱ្យមានការប្រែប្រួលថ្មីដល់កិច្ចការសភា និងនយោបាយ ដែលទាមទារឱ្យព្រឹទ្ធសភាចាំបាច់ត្រូវវិវឌ្ឍន៍ខ្លួនប្រកបដោយភាពតំណាង តម្លាភាព ភាពចូលជិតបាន គណនេយ្យភាព ប្រសិទ្ធភាព និងជាសភាទំនើប ។

នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពរបស់ព្រឹទ្ធសភានៅក្នុងរយៈពេល១០ឆ្នាំ (២០២១-២០៣០) ព្រឹទ្ធសភាបានកំណត់ចក្ខុវិស័យគឺការអនុវត្តការងារជាប្រព័ន្ធនៃសភាទំនើបដោយឈរលើលក្ខណៈវិនិច្ឆ័យ ភាពតំណាង តម្លាភាព ភាពខិតជិតបាន គណនេយ្យភាព និងការចាត់តាំងត្រូវស្របតាមគុណតម្លៃប្រជាធិបតេយ្យ ជាមួយនឹងគោលដៅរួមមាន៖ **គោលដៅអាទិភាពទី១**-ការពង្រឹងពង្រីកមុខងារនីតិកម្ម **គោលដៅអាទិភាពទី២**-ការពង្រឹងពង្រីកមុខងារតាមដានការអនុវត្តច្បាប់ **គោលដៅអាទិភាពទី៣**-ការពង្រឹងពង្រីកមុខងារតំណាង **គោលដៅអាទិភាពទី៤**-ការពង្រឹងពង្រីកមុខងារសហប្រតិបត្តិការ អន្តរជាតិ និងទំនាក់ទំនងសាធារណៈ **គោលដៅអាទិភាពទី៥**-ការពង្រឹងពង្រីកមុខងារអភិវឌ្ឍន៍ស្ថាប័ន។ បន្ថែមពីនេះ ព្រឹទ្ធសភាមានសុទិដ្ឋិនិយម និងចក្ខុវិស័យផ្តោតការចាប់យកបច្ចេកវិទ្យាព័ត៌មានមកប្រើប្រាស់ ដើម្បីចូលរួមចំណែកនៅក្នុងដំណើរការអនុវត្តគោលដៅអាទិភាពទាំងប្រាំឱ្យទទួលបានជោគជ័យ និងសមិទ្ធផលថ្មីៗបន្ថែមទៀត។ ជាមួយគ្នានេះការបញ្ចូលបច្ចេកវិទ្យាព័ត៌មានក្នុងប្រតិបត្តិការការងាររបស់ព្រឹទ្ធសភានឹងមិនត្រឹមតែអាចជំរុញដល់ការពង្រឹងពង្រីកការងាររបស់ខ្លួនប្រកបដោយគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផលប៉ុណ្ណោះទេ ហើយវាថែមទាំងចូលរួមអនុវត្តន៍ដោយយកចិត្តទុកដាក់ខ្ពស់ទៅដល់លក្ខណៈវិនិច្ឆ័យរបស់សភាប្រជាធិបតេយ្យទំនើបមួយប្រកបដោយស្មារតីមនសិការ និងការទទួលខុសត្រូវខ្ពស់ចំពោះប្រជាពលរដ្ឋ ព្រមទាំងសង្គមជាតិផងដែរ។

ក្រោមពន្លឺនៃឯកសារមគ្គុទ្ទេសក៍ដ៏មានសារៈសំខាន់នេះ នាយកដ្ឋានព័ត៌មានវិទ្យា នៃអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ ដែលជាសេនាធិការរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានសិក្សាកសាងផែនការមេស្តីពី **«បរិវត្តកម្មព្រឹទ្ធសភាអេឡិចត្រូនិក ២០២២-២០៣០»** ដើម្បីឆ្លើយតបឱ្យបានសមស្របនឹងតម្រូវការជាសារវន្តរបស់ព្រឹទ្ធសភា និងវឌ្ឍនភាពសង្គមជាតិ នៅក្នុងកាលៈទេសៈនៃការរីកចម្រើនបច្ចេកវិទ្យាព័ត៌មាននៅក្នុងដំណើរការពង្រឹងពង្រីកគោលការណ៍នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យជ្រកក្រោមម្លប់ដ៏សុខដុមនៃសន្តិភាពរបស់កម្ពុជា។ ផែនការមេនេះបានផ្តោតទៅលើ «ទស្សនវិស័យរបស់ព្រឹទ្ធសភាសំដៅទំនើបនីយកម្មការងារព្រឹទ្ធសភាដោយប្រើប្រាស់នូវសក្តានុពល និងឧត្តមភាពនៃបច្ចេកវិទ្យាព័ត៌មាន ដើម្បីឆ្ពោះទៅជាសភាទំនើបមួយប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល ភាពបើកចំហ និងនវានុវត្តន៍»។ ផ្អែកលើទស្សនវិស័យខាងលើនេះ ផែនការមេនេះបានដាក់ចេញនូវបេសកកម្មដោយស្មារតីទទួលខុសត្រូវ និងការយកចិត្តទុកដាក់ខ្ពស់ដោយផ្តោតសំខាន់ « ការបង្កើតព្រឹទ្ធសភាអេឡិចត្រូនិកមួយ ដែលមានលក្ខណៈរឹងមាំ បើកចំហ និងនវានុវត្តន៍ ដើម្បីចូលរួមអភិវឌ្ឍន៍សង្គមជាតិកម្ពុជាប្រកបដោយនីតិរដ្ឋ ស៊ីវិល័យ វិបុលភាព

និងវឌ្ឍនភាពក្រោមដំបូលនៃសន្តិភាព»។ លើសពីនេះ ដើម្បីសម្រេចនូវទស្សនវិស័យ និងបេសកកម្មខាងលើនេះ ផែនការមេបានកំណត់នូវគោលដៅអាទិភាពចំនួនប្រាំមួយសម្រាប់ព្រឹទ្ធសភារួមមាន៖ **គោលដៅអាទិភាពទី១**-ការពង្រឹងពង្រីកហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាប្រកបដោយភាពរឹងមាំ និងមានលក្ខណៈជាប្រព័ន្ធពពក(CLOUD) **គោលដៅអាទិភាពទី២**-ការពង្រឹងពង្រីកផលិតភាពការងារ និងសេវាកម្មបច្ចេកវិទ្យាព័ត៌មាន ដើម្បីគាំទ្រមុខងារស្នូលទាំងបីរបស់ព្រឹទ្ធសភាប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈវៃឆ្លាត **គោលដៅអាទិភាពទី៣**-ពង្រឹងពង្រីកការគ្រប់គ្រង និងការទទួលយកបច្ចេកវិទ្យាព័ត៌មានសម្រាប់ព្រឹទ្ធសភា **គោលដៅអាទិភាពទី៤**-ពង្រឹងពង្រីកទំនាក់ទំនងសាធារណៈ និងព័ត៌មានដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន **គោលដៅអាទិភាពទី៥**-ការកសាងនិងអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្សរបស់ព្រឹទ្ធសភាប្រកបដោយលក្ខណៈឈ្លាសវៃ **គោលដៅអាទិភាពទី៦**-ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការភាពជាដៃគូជាមួយនឹងដៃគូពាក់ព័ន្ធ ដើម្បីពង្រឹងពង្រីកកិច្ចអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភា។

គោលដៅទាំងប្រាំមួយត្រូវបានដាក់ចេញដោយស្មារតីទទួលខុសត្រូវ និងឆ្លើយតបនឹងតម្រូវការជាតិក្នុងនាមជាអង្គនីតិប្បញ្ញត្តិរបស់កម្ពុជា ហើយគោលដៅទាំងនេះបានអនុលោមតាមមាគ៌ាឆ្ពោះទៅជាសភាទំនើបតាមរយៈការអនុវត្តជាជំហានៗ ជាពិសេសការតម្រង់ទិសដៅ និងត្រីវិស័យជាចម្បងក្លាយទៅជាសភាអេឡិចត្រូនិកបែបសភាអនឡាញ(Online Parliament) ដើម្បីពង្រីកផលិតភាពការងារ និងការប្រាស្រ័យឆ្លើយឆ្លងរបស់ព្រឹទ្ធសភាឱ្យបានទូលំទូលាយនៅឆ្នាំ២០២៥ និងជាសភាទំនើបដែលមានលក្ខណៈជាសភាបើកចំហ(Open Parliament) នៅឆ្នាំ២០៣០។

II-ទស្សនទាននៃសភាអេឡិចត្រូនិក

១-និយមន័យ

ទស្សនទានសភាអេឡិចត្រូនិក(E-Parliament)មានមូលដ្ឋានចេញពីពាក្យ E និង Parliament ដែល E សំដៅអត្ថន័យនៃពាក្យអេឡិចត្រូនិក (Electronic) និង Parliament មានន័យថា «សភា» ហើយជាទូទៅពាក្យថា «E» អាចជំនួសដោយ «Digital» ទៅជាសភាឌីជីថល (Digital Parliament) ឬក៏សភាទំនើប (Modern Parliament) ទៅតាមការនិយម និងមូលបទរបស់សភាផ្សេងៗ ដោយផ្អែកលើការយល់ឃើញលើការអនុវត្ត និងទស្សនទានរបស់សភានានា។ ទោះបីជាយ៉ាងណាក៏ដោយ និយាមនៃសភាអេឡិចត្រូនិករក្សានូវមូលដ្ឋានរួម «សភាដែលប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងបច្ចេកវិទ្យាព័ត៌មាន ដើម្បីបង្កើតនូវប្រសិទ្ធភាព និងប្រសិទ្ធផល»។ ក្រៅពីនេះពាក្យ «សភា (Parliament)» គឺជាពាក្យគន្លឹះមួយដែលបញ្ជាក់ទៅលើតួអង្គ (ស្ថាប័នសភា ឬអង្គនីតិប្បញ្ញត្តិ) ហើយតោងគិតអំពីសភាជាអង្គនីតិប្បញ្ញត្តិដែលមានមុខងារស្នូលបីសំខាន់ ១. មុខងារនីតិកម្ម(ការបង្កើត និងអនុម័តច្បាប់) ២.មុខងារត្រួតពិនិត្យ (តាមដានការអនុវត្តច្បាប់ ឬគោលនយោបាយផ្សេងៗរបស់រាជរដ្ឋាភិបាល) និង៣.មុខងារតំណាង (តំណាងឱ្យប្រជាពលរដ្ឋ និងធ្វើដើម្បីប្រជាពលរដ្ឋ)។ តាមទស្សនៈនេះសភាអេឡិចត្រូនិកជាការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាឌីជីថល ដើម្បីជំរុញ និងលើកកម្ពស់ដល់មុខងារស្នូលរបស់សភា ឬអង្គនីតិប្បញ្ញត្តិ ឱ្យកាន់តែមានប្រសិទ្ធផល និងប្រសិទ្ធភាពប្រសើរជាងមុន។ សម្រាប់សភាមួយចំនួន សភាអេឡិចត្រូនិកបានកើតចេញពីគំនិតចម្បងទាក់ទងនឹងការបង្កើតនូវទម្រង់អត្ថបទ និងវដ្តនៃការកសាងឯកសារច្បាប់(Production Chain) ទៅជាលក្ខណៈ

ឌីជីថលដើម្បីគាំទ្រដល់សកម្មភាពការងារនីតិកម្មរបស់សមាជិកសភា ដោយចាប់ផ្តើមពីដំណើរការនៃការរៀបចំសេចក្តីព្រាងច្បាប់រហូតដល់ការងារបកប្រែ ហើយផ្តល់មូលដ្ឋានផ្ទៀងផ្ទាត់ និងការងារបកប្រែឯកសារ មុននឹងឈានដល់ការផ្សព្វផ្សាយ ឬចែកចាយ ដែលមានលក្ខណៈជាទម្រង់ឌីជីថល (XML Content)។

ក្នុងបរិការណ៍នៃសង្គមព័ត៌មាន (Information Society) នាំមកនូវការលេចវត្តមានដ៏ត្រដែត និងពេញនិយមនៃបណ្តាញសង្គមនិងបច្ចេកវិទ្យាឌីជីថលថ្មីៗ តាមរយៈការប្រើប្រាស់បណ្តាញអ៊ីនធឺណិតដោយផ្តោតលើការចែកចាយព័ត៌មាន និងការចូលរួមក្រោមទស្សនវិស័យ«ប្រជាធិបតេយ្យអេឡិចត្រូនិក(E-Democracy) និងការចូលរួមឌីជីថល(E-participation)» ដែលបាននាំឱ្យប្រជាពលរដ្ឋ និងសភាបានកាន់តែជិតដិត និងស្និទ្ធស្នាលគ្នាជាងពេលកន្លងទៅ។ សភាអេឡិចត្រូនិកបានផ្តោតទៅលើទស្សនសភាដែលប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងគោលដៅ បើកចំហតម្លាភាព និងគណនេយ្យភាព។ ជាមួយនឹងសក្តានុពលនៃបច្ចេកវិទ្យាព័ត៌មាន ដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពដើម្បីភ្ជាប់សភាជាមួយប្រជាពលរដ្ឋនៅគ្រប់ស្រទាប់សង្គមឱ្យទទួលបាននូវព័ត៌មាន និងចំណេះដឹងប្រកបដោយគុណភាពទាក់ទងនឹងសកម្មភាពការងារប្រចាំថ្ងៃរបស់សភាផងដែរ។ ជាមួយគ្នានេះ សភាអេឡិចត្រូនិក គឺជាអង្គនីតិប្បញ្ញត្តិមួយប្រកបដោយប្រសិទ្ធផល និងជាស្ថានដ៏សំខាន់មួយដែលគ្រប់ភាគីពាក់ព័ន្ធសភាមានការប្រាស្រ័យឆ្លើយឆ្លងតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាទូរគមនាគមន៍ ដើម្បីបំពេញការងារ និងចូលរួមក្នុងការងារស្នូលរបស់សភា (នីតិកម្ម តំណាង និងត្រួតពិនិត្យ) ប្រកបដោយប្រសិទ្ធភាព និងភាពជាក់ស្តែង។ លើសពីនេះតាមរយៈសុហ្វែរឬកម្មវិធីនៃបច្ចេកវិទ្យាឌីជីថលទំនើបៗ ស្តង់ដារ និងការទទួលយកនូវគោលនយោបាយឌីជីថលផ្សេងៗពីបណ្តាសភាអេឡិចត្រូនិកទាំងឡាយបាននាំមកនូវវឌ្ឍនភាពប្រកបដោយបរិយាបន្ន និងសមភាពសង្គម។ យោងតាមវិទ្យាស្ថានអឺរ៉ុបសម្រាប់ការស្រាវជ្រាវសភា និងឯកសារ (ECPRD 2008) សភាអេឡិចត្រូនិកគឺជាការផ្តោតទៅលើសេចក្តីរំពឹងទុកមួយរបស់អង្គនីតិប្បញ្ញត្តិដែលប្រមូលផ្តុំគ្រប់តួអង្គ និងដំណើរការផ្សេងៗរបស់សភាទាំងក្នុង-ក្រៅឆ្លងកាត់តាមអន្តរកម្មដោយបច្ចេកវិទ្យាព័ត៌មាន បច្ចេកវិទ្យាឌីជីថល ព្រមទាំងស្តង់ដារផ្សេងៗ ក្នុងគោលដៅទទួលបាននូវតម្លាភាព គុណភាព ជាតុចូលពេញលេញ ប្រសិទ្ធផល និងប្រសិទ្ធភាព។

ឆ្លងកាត់តាមការអនុវត្តជាង១០ឆ្នាំចុងក្រោយ តម្លៃនិយាមនៃសភាអេឡិចត្រូនិកបានប្រែប្រួលទៅតាមកត្តាមួយចំនួនមានជាអាទិ៍ បច្ចេកវិទ្យាឌីជីថលថ្មីៗ បទពិសោធន៍នៃការអនុវត្តរបស់សភានានា និងតម្លៃនៃភាពជាដៃគូសភា កិច្ចសហប្រតិបត្តិការអន្តរជាតិដ៏មានប្រសិទ្ធភាពតាមគន្លងនៃសកលភាវូបនីយកម្ម និងសមាហរណកម្មតំបន់ព្រមទាំងរបត់ថ្មីនៃដំណើរការពិភពលោក ដែលកត្តាទាំងអស់នេះ បានលើកតម្កើងតម្លៃ និងនិយមន័យបន្ថែមទៅលើសភាអេឡិចត្រូនិកមួយកម្រិតទៀត។ យោងតាមអន្តរសភា (IPU ២០១៨) សភាអេឡិចត្រូនិកជាបណ្តុំនៃបច្ចេកវិទ្យាចំណេះដឹង និងស្តង់ដារផ្សេងៗដែលប្រើប្រាស់ក្នុងដំណើរការការងារសភា ហើយបានបង្កើតតម្លៃនៃភាពជាដៃគូប្រកបដោយបរិយាបន្ន ការចូលរួម ព្រមទាំងការបើកចំហទៅរកប្រជាពលរដ្ឋ។

សម្រាប់ព្រឹទ្ធសភា សភាអេឡិចត្រូនិកមិនគ្រាន់តែជាការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាឌីជីថលគាំទ្រដល់មុខងារស្នូលរបស់ព្រឹទ្ធសភា មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាងឱ្យទទួលបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលប៉ុណ្ណោះទេ វាថែមទាំងជាការបន្តបោះជំហានប្រកបដោយឆន្ទៈ និងការប្តេជ្ញាចិត្តប្រកបដោយការទទួលខុសត្រូវខ្ពស់ជូនជនរួមជាតិ និងប្រទេសជាតិ ដើម្បីចូលរួមកសាងសង្គមកម្ពុជាឆ្ពោះទៅរក

សង្គមសេដ្ឋកិច្ចឌីជីថលដ៏រស់រវើក ព្រមទាំងចូលរួមដោយសកម្ម និងភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជាគ្រប់ដំណាក់កាលឆ្ពោះទៅរកការពង្រឹង និងការកសាងខឿនសេដ្ឋកិច្ចដ៏រឹងមាំមួយក្រោមទស្សនវិស័យជាប្រទេសកម្រិតមធ្យមចំណូលខ្ពស់ត្រឹមឆ្នាំ២០៣០ និងជាប្រទេសចំណូលកម្រិតខ្ពស់ឆ្នាំ២០៥០ ។ ក្នុងអត្ថន័យនេះ សភាអេឡិចត្រូនិក ឬព្រឹទ្ធសភាអេឡិចត្រូនិក គឺជាការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ឬបច្ចេកវិទ្យាឌីជីថល ដើម្បីលើកកម្ពស់ប្រតិបត្តិការ និងផលិតភាពការងារព្រឹទ្ធសភាប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងគោលបំណងឆ្លើយតបនឹងតម្រូវការប្រជាពលរដ្ឋ និងសង្គមជាតិប្រកបដោយភាពចូលជិតបាន ភាពបើកចំហ និងគណនេយ្យភាព ដែលតោងគិតដល់កិច្ចសហការ និងភាពជាដៃគូជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងក្នុងកម្រិតជាតិ-អន្តរជាតិដោយស្មារតីភាពជាដៃគូកម្រិតខ្ពស់។

បន្ថែមពីនេះ យោងតាមការអនុវត្តនៅសភានានា និងមូលដ្ឋាននៃការអភិវឌ្ឍបច្ចេកទេសជាសកលសភាអេឡិចត្រូនិកត្រូវបានកំណត់ជាជំហានៗដូចខាងក្រោម៖

- **សភាអេឡិចត្រូនិកកម្រិតទី១ ឬសភាឌីជីថល** (Digital Parliament)៖ ជាកម្រិតដំបូងនៃសភាអេឡិចត្រូនិកដោយផ្ដោតលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងឧបករណ៍ឌីជីថលសម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការ និងការងាររដ្ឋបាលសភា ប្រកបដោយភាពរហ័ស និងប្រសិទ្ធភាព ។
- **សភាអេឡិចត្រូនិកកម្រិតទី២ ឬសភាអនឡាញ** (Online Parliament)៖ ជាកម្រិតបន្ទាប់ដែលជាការបោះជំហានរបស់សភាមានប្រព័ន្ធបណ្ដាញផ្ទៃក្នុងរឹងមាំ និងសេវាកម្មបច្ចេកវិទ្យាព័ត៌មានភ្ជាប់នឹងបណ្ដាញអ៊ីនធឺណិត ដើម្បីផ្ដល់លទ្ធភាពជូនសមាជិកសភា មន្ត្រីសភា និងប្រជាពលរដ្ឋបានប្រើប្រាស់ដោយប្រសិទ្ធភាព ប្រសិទ្ធផល និងសន្សំសំចៃ។
- **សភាអេឡិចត្រូនិកកម្រិតទី៣ ឬសភាបើកចំហ** (Open Parliament)៖ ជាដំណាក់កាលដែលសភាប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានតាមលក្ខណៈប្រព័ន្ធទិន្នន័យបើកចំហ។ វាមិនគ្រាន់តែឱ្យប្រជាពលរដ្ឋទទួលបាននូវព័ត៌មាន និងកិច្ចការសព្វសារពើរបស់សភាប្រកបដោយតម្លាភាព និងប្រសិទ្ធភាពប៉ុណ្ណោះទេ វាថែមទាំងបង្កើននូវអន្តរកម្មទំនាក់ទំនងរវាងសភា និងប្រជាពលរដ្ឋកាន់តែមានលក្ខណៈជិតដិតដោយឈរលើមូលដ្ឋានសភាជាបង្អែករបស់ប្រជាពលរដ្ឋ។
- **សភាអេឡិចត្រូនិកកម្រិតទី៤ ឬសភានវានុវត្តន៍** (Innovative Parliament)៖ ជាដំណាក់កាលមួយដែលសភាមានភាពសកម្ម ប្រកបដោយភាពច្នៃប្រឌិតខ្ពស់ និងធ្វើនវានុវត្តន៍បច្ចេកវិទ្យាព័ត៌មានសំដៅទំនើបនីយកម្មការងាររបស់ខ្លួនឆ្លើយតបនឹងផលប្រយោជន៍ជាតិ និងសមូហភាពការងារក្នុងកម្រិតតំបន់ និងពិភពលោក។
- **សភាអេឡិចត្រូនិកកម្រិតទី៥ សភាទំនើប ឬសភាស្វ័យប្រវត្តិ** (Modern Parliament & Ubiquitous) ជាដំណាក់កាលដែលសភាបានបើកចំហដោយទូលំទូលាយ និងមានបច្ចេកវិទ្យាព័ត៌មានស្វ័យប្រវត្តិ ដូចជាបញ្ញាសិប្បនិម្មិត(AI)បច្ចេកវិទ្យាទិន្នន័យទូលំទូលាយ(Big Data) និងបច្ចេកវិទ្យាថ្មីៗ។

២-បច្ច័យវិជ្ជមាននៃសភាអេឡិចត្រូនិក

ជាទូទៅសង្គមព័ត៌មាន (Information Society) ត្រូវបានគេកំណត់ថា ជាសង្គមមួយដែលមានការប្រើប្រាស់ការបង្កើត ការចែកចាយ និងការធ្វើនិយាមកម្មព័ត៌មាននៅក្នុងសកម្មភាពនានាក្នុងសង្គម ហើយការប្រើប្រាស់

ព័ត៌មាន និងបច្ចេកវិទ្យាទូរគមនាគមន៍បានជះឥទ្ធិពល និងផលវិជ្ជមានលើផ្នែកជាច្រើនដល់សង្គមដូចជាៈ ការអប់រំ សេដ្ឋកិច្ច សុខាភិបាល សេវាសាធារណៈ(រដ្ឋាភិបាល) និងការរីកចម្រើននៃលទ្ធិប្រជាធិបតេយ្យជាដើម។ ផ្សាភ្ជាប់នឹងបរិការណ៍សង្គមព័ត៌មាន សភាអេឡិចត្រូនិកបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមពង្រឹងពង្រីកមុខងាររបស់ស្ថាប័ននីតិប្បញ្ញត្តិតាមរយៈការបង្កើនផលិតភាពការងារនីតិកម្មជាជាងទម្រង់ប្រពៃណីបុរាណ ដើម្បីឱ្យសង្គមមួយមានដំណើរការប្រកបដោយនីតិរដ្ឋ ភាពសុខដុម និងភាពយុត្តិធម៌។ ក្រោមឥទ្ធិពលនៃសង្គមព័ត៌មាន សភាអេឡិចត្រូនិកគឺជាភ្នាក់ងារ (Intermediate Connection)សង្គម ដើម្បីភ្ជាប់ជាមួយគ្នារវាងស្ថាប័ន មនុស្ស សេវាកម្ម និងអ្វីផ្សេងៗជាច្រើនទៀត។ ជាក់ស្តែង ការបន្តអភិវឌ្ឍន៍ និងទទួលយកសភាអេឡិចត្រូនិកយ៉ាងច្រើនពីបណ្តាសភានានា មិនគ្រាន់តែសភាមកពីប្រទេសអភិវឌ្ឍន៍ ឬកំពុងអភិវឌ្ឍន៍ក៏ដោយក្តី លទ្ធផលបានបង្ហាញថា វត្តមានរបស់សភាអេឡិចត្រូនិកបានចូលរួមយ៉ាងសកម្មក្នុងការបង្រួមគម្លាតសង្គមក្នុងរង្វង់ប្រជាពលរដ្ឋក្នុងសង្គម និងគម្លាតសភាក្នុងរង្វង់ជាមួយនឹងគ្រប់ភាគីពាក់ព័ន្ធរបស់សភា តាមរយៈការពង្រឹងបរិយាបន្នសង្គមមួយឱ្យមានលក្ខណៈតម្លាភាព ភាពបើកចំហ និងគណនេយ្យភាពតាមគន្លងនៃប្រជាធិបតេយ្យ និងនីតិរដ្ឋក្រោមពាក្យស្លោក «បច្ចេកវិទ្យាព័ត៌មានសម្រាប់ទាំងអស់គ្នា»។

តាមរយៈការស្ទង់មតិអំពីវឌ្ឍនភាពនៃសភាអេឡិចត្រូនិកចាប់តាំងពីឆ្នាំ២០១០-២០១៨ របស់សភានានាកម្រិតពិភពលោក កម្រិតក្រុមសភាសមាជិក (PMO) និងក្រុមសភាមិនមែនសមាជិក (Non-PMO) នៃក្រុមទទួលការវាយតម្លៃដោយអង្គការអន្តរសភា(IPU) បានបង្ហាញថាប្រសិទ្ធភាព និងប្រសិទ្ធផល នៃសភាអេឡិចត្រូនិកបានកើនឡើងគួរឱ្យកត់សម្គាល់ទាក់ទងនឹងប្រតិបត្តិការការងាររដ្ឋបាល ការងារទំនាក់ទំនងសាធារណៈ និងការងារអន្តរជាតិរបស់សភា ជាពិសេសនោះសភានានាបាននឹងកំពុងធ្វើនវានុវត្តន៍លើប្រតិបត្តិការសភារបស់ខ្លួនដោយសកម្ម និងមានភាពបត់បែនខ្ពស់។ តាមរយៈលទ្ធផលនេះបានបង្ហាញថា សភាអេឡិចត្រូនិកជាមូលដ្ឋានសំខាន់សម្រាប់ប្រើប្រាស់ក្នុងជីវភាពសភាភ្ជាប់ជាមួយនឹងគំនិតច្នៃប្រឌិត និងការអនុវត្តល្អៗ ដោយឈរលើមូលដ្ឋានសំយោគរវាងច្បាប់ ប្រពៃណីទំនៀមទម្លាប់ វប្បធម៌ និងបច្ចេកវិទ្យាព័ត៌មានរបស់ប្រទេស និងសភានីមួយៗ ក្នុងទិសដៅកសាងទំនុកចិត្តនិងភាពជឿជាក់ជូនប្រជាពលរដ្ឋរៀងៗខ្លួន។ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ឬក៏សភាអេឡិចត្រូនិកបានភ្ជាប់ទៅដល់កិច្ចសហការទ្វេភាគី ឬពហុភាគី ដែលឆ្លើយតបនឹងផលប្រយោជន៍រួម និងនិយាយដោយឡែកគឺផលប្រយោជន៍ទ្វេភាគីនៃបណ្តាសភានីមួយៗ ឧទាហរណ៍ៈ ការផ្តល់ជំនួយបច្ចេកទេសសម្ភារៈ និងការចែករំលែកទិន្នន័យរវាងសភា-សភា សភា និងអង្គការអន្តរជាតិនានាជាដើម។

III-បច្ចេកវិទ្យាព័ត៌មាន និងមុខងារព្រឹទ្ធសភា

១-បច្ចេកវិទ្យាព័ត៌មាន និងមុខងារនីតិកម្ម

មុខងារនីតិកម្មជាមុខងារស្នូលរបស់ព្រឹទ្ធសភាដែលមានតួនាទីក្នុងការពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរួមរបស់ប្រជាពលរដ្ឋ និងសង្គមជាតិទាំងមូល។ ដូច្នេះព្រឹទ្ធសភាត្រូវមានសមត្ថភាពពេញលេញភ្ជាប់នឹងមធ្យោបាយគ្រប់គ្រាន់ក្នុងការពិនិត្យ និងការឱ្យយោបល់លើគ្រប់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដោយត្រូវមានព័ត៌មានគ្រប់ជ្រុងជ្រោយ ជាពិសេសការសិក្សាអំពីផលប៉ះពាល់នៃច្បាប់(RIA)

តាមរយៈក្រុមការងារស្រាវជ្រាវ និងមន្ត្រីស្រាវជ្រាវ ដើម្បីបម្រើជាជំនួយស្មារតីរឹងមាំជូនសមាជិកព្រឹទ្ធសភាបានប្រើប្រាស់នៅក្នុងសម័យប្រជុំព្រឹទ្ធសភា គណៈកម្មការ ក្រុមពិភាក្សា និងការសិក្សាដោយឡែករបស់សមាជិកម្នាក់ៗ។ រាល់សម័យប្រជុំព្រឹទ្ធសភា ឯកសារសព្វសារពើ និងព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងរបៀបវារៈ និងខ្លឹមសារពិភាក្សាត្រូវរៀបចំឱ្យបានទាន់ពេលវេលាជូនអង្គប្រជុំ និងអ្នកពាក់ព័ន្ធ។ បន្ថែមពីនេះ ដំណើរការនៃកិច្ចប្រជុំត្រូវប្រព្រឹត្តទៅដោយឈរលើមូលដ្ឋានរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ក្រមសីលធម៌ និងមូលដ្ឋានច្បាប់ជាធរមាន ដោយគោងគិតដល់ការប្រើប្រាស់ពេលវេលាប្រកបដោយប្រសិទ្ធផល។ រាល់ខ្លឹមសារនៃកិច្ចប្រជុំត្រូវបានកត់ត្រាច្បាស់លាស់ដោយបែងចែកជាបីទម្រង់គឺ **វីដេអូ សំឡេង និងខ្លឹមសារអក្សរ** ដើម្បីផ្សព្វផ្សាយជូនសាធារណជនជ្រាបក្រោយកិច្ចប្រជុំ និងទុកដាក់ឱ្យមានសុវត្ថិភាពប្រើប្រាស់សម្រាប់កែសម្រួល ព្រមទាំងស្វែងរកឡើងវិញ។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យ (D-Repository) ប្រព័ន្ធទិន្នន័យច្បាប់ ប្រព័ន្ធបណ្ដាញរដ្ឋបាលផ្ទៃក្នុង (Intranet) សុហ្វែរបណ្ណាល័យអេឡិចត្រូនិក(E-Library) សុហ្វែរបណ្ណសារដ្ឋានអេឡិចត្រូនិក(E-Archive) ប្រព័ន្ធគ្រប់គ្រងកិច្ចប្រជុំ (Paperless-System) ទិន្នន័យរបាយការណ៍ពិស្តារ (Minute Report Database) និងសុហ្វែរផ្សេងៗទៀតត្រូវរៀបចំជាបន្តបន្ទាប់ និងឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នាតាមលំដាប់លំដោយស្របនឹងអាទិភាពរបស់ព្រឹទ្ធសភា។ ជាងនេះទៅទៀតការលើកកម្ពស់ការងារនីតិកម្មព្រឹទ្ធសភា និងការផ្ដល់ព័ត៌មានជូនសមាជិកគ្រប់រូបត្រូវមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ ព្រឹទ្ធសភាចាំបាច់ត្រូវមានការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីផ្ដល់តម្រូវការរបស់អតិថិជនមានជាអាទិ៍៖ ១-ការរៀបចំបង្កើតឱ្យមានប្រព័ន្ធពិនិត្យសេចក្ដីព្រាងច្បាប់ (ICT-based drafting system) ២-ប្រព័ន្ធគ្រប់គ្រងដំណើរការពិនិត្យ និងឱ្យយោបល់សេចក្ដីព្រាងច្បាប់ឬសេចក្ដីស្នើច្បាប់(Bill Tracking System) និង៣-ប្រព័ន្ធគ្រប់គ្រងឯកសារបែបលក្ខណៈពពក(DMS)។ ចំពោះមធ្យោបាយឌីជីថលមួយចំនួនត្រូវធ្វើបុរេសកម្មសម្រាប់ត្រៀមនូវមធ្យោបាយ និងយន្តការឌីជីថលដ៏មានប្រសិទ្ធភាពជាមុន ដើម្បីធានាប្រក្រតីភាពស្ថាប័ន ជាពិសេសការធានាប្រក្រតីភាពដំណើរការនីតិកម្ម និងការងារផ្សេងៗរបស់ស្ថាប័នក្នុងកាលៈទេសៈប្រធានស័ក្តិដូចជា៖ សន្តិសុខនយោបាយ ការដាក់ប្រទេសក្នុងគ្រាមានអាសន្ន គ្រោះធម្មជាតិ គ្រោះមហន្តរាយសុខាភិបាល និងហានិភ័យផ្សេងៗ។ ព្រឹទ្ធសភាត្រូវមានប្រព័ន្ធប្រជុំពីចម្ងាយ និងប្រព័ន្ធផ្សេងៗទៀត ដោយប្រើប្រាស់ថ្នាល និងសុហ្វែរប្រកបដោយភាពជឿជាក់ជាមួយនឹងទំនុកចិត្តខ្ពស់ ដើម្បីធានាថាការផ្ដិតយករូបភាព និងសំឡេងបានច្បាស់ល្អ ព្រមទាំងបានរក្សាទុកឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាពសម្រាប់ផ្ដល់ភាពងាយស្រួលប្រើប្រាស់ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។ ជាមួយគ្នានេះសេវាកម្មឌីជីថលចាំបាច់មួយចំនួនត្រូវរៀបចំផងដែរដូចជា៖ ប្រព័ន្ធបោះឆ្នោត និងការអនុម័តបែបឌីជីថលត្រូវដំណើរការ ដោយរលូន ងាយស្រួល សុវត្ថិភាព និងអត្តសញ្ញាណកម្មឌីជីថលប្រកបដោយភាពត្រឹមត្រូវ។

សម្រាប់គណៈកម្មការជំនាញនីមួយៗរបស់ព្រឹទ្ធសភាដែលដើរតួនាទីជាកូនព្រឹទ្ធសភា (Mini Senate) ក្នុងការសិក្សាស្រាវជ្រាវ និងផ្ដល់យោបល់ទៅលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់។ ទាក់ទងនឹងការងារនេះ គណៈកម្មការចាំបាច់ត្រូវប្រើប្រាស់រាល់ឯកសារ និងព័ត៌មានដែលជាសក្ខីកម្មត្រូវមានប្រភពច្បាស់លាស់ ហើយការសំណេះសំណាល និងការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងអាជ្ញាធរក្រសួង-ស្ថាប័នមានសមត្ថកិច្ចផ្សេងៗ ដោយមានការកត់ត្រាទុកដាក់ និងថែរក្សារបាយការណ៍ឱ្យបានត្រឹមត្រូវសម្រាប់ការសិក្សាស្រាវជ្រាវ ឈ្វេងយល់ ដោះស្រាយ ព្រមទាំងប្រើប្រាស់សម្រាប់ការផ្សព្វផ្សាយជូនប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធផង។

គណៈកម្មការជំនាញរបស់ព្រឹទ្ធសភា ត្រូវបន្តបង្កើនគុណភាពគេហទំព័រដែលប្រមូលផ្តុំនូវមាតិកាព័ត៌មានសំខាន់ៗរបស់គណៈកម្មការ ដើម្បីប្រើប្រាស់ជាមធ្យោបាយសម្រាប់តម្កល់ទុកឯកសារក៏ដូចជាធ្វើការផ្សព្វផ្សាយជូនដល់សាធារណជនបានយល់ដឹងអំពីភារកិច្ច និងលទ្ធផលសម្រេចបានផងដែរ។

ជារួមកិច្ចប្រជុំ និងរបៀបរបបការងារផ្សេងៗសម្រាប់គ្រប់យន្តការទាំងអស់របស់ព្រឹទ្ធសភាទាក់ទងនឹងការងារនីតិកម្មត្រូវបន្តប្រកាន់ភ្ជាប់នូវគោលការណ៍ប្រសិទ្ធភាព ប្រសិទ្ធផល និងការសន្សំសំចៃ ជាពិសេសការកាត់បន្ថយក្រដាស និងទឹកថ្នាំបោះពុម្ពជាអតិបរិមា ដោយប្រែក្លាយទៅជាមាតិកាឌីជីថល(Digital Contents) និងការកាត់បន្ថយការប្រើប្រាស់អគ្គិសនីដែលជាកត្តាចូលរួមការគាំពារដល់បរិស្ថានក៏ដូចជាការកើនឡើងសីតុណ្ហភាព។ ការប្រើប្រាស់សុហ្វែរព័ត៌មានវិទ្យានឹងជួយដល់សមាជិកព្រឹទ្ធសភា និងគណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភាអាចស្វែងរក និងប្រើប្រាស់ដោយប្រសិទ្ធភាពគ្រប់ពេលវេលា និងគ្រប់កាលៈទេសៈ។

២-បច្ចេកវិទ្យាព័ត៌មាន និងមុខងារតាមដានការអនុវត្តច្បាប់

មុខងារតាមដានការអនុវត្តច្បាប់មានទំនាក់ទំនង និងឆ្លើយឆ្លងឱ្យគ្នាទៅវិញទៅមកជាមួយនឹងមុខងារនីតិកម្ម។ នៅដំណាក់កាលដែលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ត្រូវបានអនុម័តរហូតទៅជាច្បាប់ជាធរមាន ព្រឹទ្ធសភាត្រូវការតាមដានការអនុវត្តច្បាប់របស់រាជរដ្ឋាភិបាល ថាតើវិសាលភាពអនុវត្តច្បាប់បានល្អប្រសើរ និងផលប៉ះពាល់កម្រិតណាដល់ប្រជាពលរដ្ឋ និងសង្គមជាតិ។ នៅក្នុងន័យនេះ ព្រឹទ្ធសភាត្រូវមានសមត្ថភាពគ្រប់គ្រាន់លើការងារស្រាវជ្រាវ ប្រមូលព័ត៌មាន វិភាគ សំយោគ វាយតម្លៃ និងផ្តល់អនុសាសន៍ដល់ដំណើរការរបស់រាជរដ្ឋាភិបាល។ គណៈកម្មការជំនាញ និងសមាជិកព្រឹទ្ធសភាត្រូវមានលទ្ធភាពគ្រប់គ្រាន់ និងគ្រប់រូបភាព ដើម្បីទទួលបាននូវព័ត៌មាន និងឯកសារផ្សេងៗពីក្រសួងស្ថាប័នថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិឱ្យបានទាន់ពេលវេលា។ ព្រឹទ្ធសភាត្រូវមានប្រព័ន្ធទិន្នន័យ ដែលមានលក្ខណៈពិសេស និងបានធ្វើសង្គតិភាពទិន្នន័យ (Data Integration) ជាមួយនឹងបណ្តាញទិន្នន័យថ្នាក់ជាតិ-ក្រោមជាតិរបស់រាជរដ្ឋាភិបាលតាមរយៈថ្នាលឌីជីថល និងប្រព័ន្ធរាជរដ្ឋាភិបាលឌីជីថលដោយធ្វើអន្តរទំនាក់ទំនងជាមួយនឹងមជ្ឈមណ្ឌលព័ត៌មានវិទ្យារបស់ព្រឹទ្ធសភា និងប្រព័ន្ធផ្ទៃក្នុងរបស់ព្រឹទ្ធសភា (Intranet) ព្រមទាំងការប្រើប្រាស់ផតថល (portal) មួយប្រកបដោយសុវត្ថិភាព និងភាពចុះសម្រុងគ្នាក្នុងគោលបំណងប្រើប្រាស់ទិន្នន័យអស់ទាំងនោះ ដើម្បីជាជំនួយដល់ការងារគណៈកម្មការជំនាញនីមួយៗរបស់ព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភាមានលទ្ធភាពទទួលបាននូវព័ត៌មាន និងធាតុចូលគ្រប់គ្រាន់សម្រាប់ការពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ព្រមទាំងការតាមដានការអនុវត្តច្បាប់កាន់តែមានប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយដែលជាឧត្តមប្រយោជន៍ជូនសង្គមជាតិ និងប្រជាពលរដ្ឋ។ ក្នុងនាមជាស្ថាប័ននីតិប្បញ្ញត្តិរបស់កម្ពុជា ព្រឹទ្ធសភា និងរដ្ឋសភាត្រូវខិតខំកសាងរួមគ្នានូវមធ្យោបាយ និងឧបករណ៍ឌីជីថលផ្សេងៗ ជាពិសេសការកសាង និងធ្វើសង្គតិភាពប្រព័ន្ធតែមួយដើម្បីផ្លាស់ប្តូរទិន្នន័យ និងធានាវិលហូរឯកសារផ្សេងៗរវាងគ្នានឹងគ្នាឱ្យបានទាន់ពេលវេលា និងឆាប់រហ័ស។

ព្រឹទ្ធសភាត្រូវរួមជាមួយនឹងរដ្ឋសភាក្នុងការតាមដានពិនិត្យការប្រើប្រាស់ថវិកាជាតិរបស់រាជរដ្ឋាភិបាលតាមរយៈការវាយតម្លៃ និងសិក្សាលើការងារនេះជាប្រចាំ ព្រមទាំងចាំបាច់ត្រូវមានលទ្ធភាពទទួលបាននូវព័ត៌មានគ្រប់ជ្រុងជ្រោយដែលផ្តល់ដោយក្រសួងស្ថាប័នចំណុះរាជរដ្ឋាភិបាល ជាពិសេសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័ន ដែល

បម្រើសេវាសាធារណៈសំខាន់ៗ ដោយភ្ជាប់នូវសូចនាករ និងលទ្ធផលការងារ ដើម្បីផ្តល់ភាពងាយស្រួលពិនិត្យលើវឌ្ឍនភាពការងាររបស់រាជរដ្ឋាភិបាលឱ្យកាន់តែល្អប្រសើរ។ ចំពោះឯកសារស្ថិតិទិន្នន័យត្រូវទុកដាក់ជាឯកសារកាលប្បវត្តិ និងប្រវត្តិកត់ត្រាទិន្នន័យក្នុងប្រព័ន្ធដែលមានលក្ខណៈជាប្រព័ន្ធស្វ័យប្រវត្តិ និងទិន្នន័យមានលក្ខណៈប្រទាក់ក្រឡា (Schema) ដើម្បីផ្តល់លទ្ធភាពដល់ការវិភាគ និងស្រាវជ្រាវកាន់តែល្អប្រសើរ ព្រមទាំងសម្រាប់ចងក្រងជាជំនួយស្មារតីស្តីពីថវិកាជាតិនៅដំណាក់កាលមុនដំណាច់ឆ្នាំនីមួយៗ តាមរយៈនាយកដ្ឋានថវិកាសភារបស់ព្រឹទ្ធសភាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា គណៈកម្មការទី២ព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភាសម្រាប់ប្រើប្រាស់ក្នុងការត្រួតពិនិត្យ និងឱ្យយោបល់លើច្បាប់ថវិកាប្រកបដោយភាពត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយតាមបទដ្ឋានបច្ចេកទេសថវិកា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់រាជរដ្ឋាភិបាល និងប្រទេសជាតិ។

៣-បច្ចេកវិទ្យាព័ត៌មាន និងមុខងារតំណាង

មុខងារតំណាងជាមុខងារដ៏មានសារៈសំខាន់សម្រាប់ព្រឹទ្ធសភា ដោយតម្រូវឱ្យព្រឹទ្ធសភាត្រូវបំពេញតួនាទីជាតំណាងឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋទូទាំងប្រទេស។ ព្រឹទ្ធសភាត្រូវយកចិត្តទុកដាក់ពង្រឹងគុណភាពការទំនាក់ទំនងជិតស្និទ្ធជាមួយនឹងប្រជាពលរដ្ឋ និងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីរួមគ្នាលើកកម្ពស់កិត្យានុភាពស្ថាប័នផង និងចូលរួមក្នុងដំណើរការពង្រឹងពង្រីកគោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋ។ ការរៀបចំវិធីសាស្ត្រផ្សព្វផ្សាយ និងបង្កើតមាតិកាព័ត៌មានប្រកបដោយភាពចម្រុះ និងទម្រង់ថ្មីៗបែបឌីជីថលមានដូចជា ការចងក្រងកូនសៀវភៅទស្សនាវដ្តី វីដេអូ សំឡេង ដើម្បីផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ គេហទំព័រ សារអេឡិចត្រូនិកព្រមទាំងបណ្តាញសង្គមនានា កត្តាទាំងនេះធ្វើឱ្យការទទួលព័ត៌មានរបស់ប្រជាពលរដ្ឋកាន់តែទូលំទូលាយ និងឆាប់រហ័សជាងមុន។ គេហទំព័រព្រឹទ្ធសភា ត្រូវមានលក្ខណៈគ្រប់ជ្រុងជ្រោយ ភាពបត់បែនរហ័ស និងងាយស្រួលនៅក្នុងការប្រើប្រាស់ដែលធានាដល់ប្រសិទ្ធភាពនៃការប្រមូលផ្តុំព័ត៌មានសំខាន់ៗ និងសកម្មភាពទូទៅរបស់ព្រឹទ្ធសភា ជាពិសេសបង្កលក្ខណៈសម្បត្តិបច្ចេកទេសខ្ពស់ដល់ក្រុមអសមត្ថភាព ឬខ្វះនីតិសម្បទាមានជាអាទិ៍៖ ចាស់ជរា អក្ខរជន កុមារ និងជនពិការឱ្យទទួលបានព័ត៌មានទាន់ពេលវេលា និងត្រឹមត្រូវ។ ឯកសារគតិយុត្ត ច្បាប់ និងគោលនយោបាយផ្សេងៗ ត្រូវបន្តបញ្ចូល និងផ្សព្វផ្សាយឱ្យបានទូលំទូលាយជូនសាធារណជនតាមរយៈប្រព័ន្ធឌីជីថលបែបទិន្នន័យ(XML) និងទិន្នន័យឌីជីថលដើម(Digital Born) ជាដើម។ ក្នុងដំណើរការពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ព្រឹទ្ធសភាត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធតាមរយៈការប្រមូលមតិយោបល់ តម្រូវការ សំណូមពរ និងទស្សនៈរបស់ប្រជាពលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល ក្រុមមនុស្សផ្សេងៗក្នុងសង្គម ដើម្បីរួមចំណែកដ៏សំខាន់ដល់ការរៀបចំ គោលនយោបាយ និងច្បាប់នានាប្រកបដោយគុណភាព និងបរិយាបន្ន។ ជាទូទៅមធ្យោបាយសុហ្វែរដ៏មានប្រសិទ្ធភាពនិងប្រជាប្រិយភាពនៅក្នុងការប្រមូលផ្តុំនូវមតិយោបល់ និងជាតុចូលពីប្រជាពលរដ្ឋមានដូចជា៖ កម្មវិធីទទួលពាក្យបណ្តឹងអេឡិចត្រូនិក(E-petition)ការបោះឆ្នោតអេឡិចត្រូនិកស្ទង់មតិ(E-voting) វេទិកាពិភាក្សាអេឡិចត្រូនិក (Electronic Discussion) គម្រោងពិគ្រោះយោបល់លើគោលនយោបាយអនឡាញ (Online Policy Consultation Project) កម្រងសំណួរអនឡាញ(Online Questionnaires) និងការជជែកពិភាក្សាជាមួយសមាជិកសភា ..។ល។

ក្នុងនាមជាតំណាងប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ-សង្កាត់ សមាជិកព្រឹទ្ធសភាគ្រប់រូបត្រូវមានទំនាក់ទំនងជាមួយនឹងមូលដ្ឋានជាប្រព័ន្ធ និងជាប្រចាំ ដើម្បីទទួលព័ត៌មានថ្មីៗពីមូលដ្ឋានទាក់ទងនឹងការលំបាកសំណូមពរផ្សេងៗ ជាពិសេសផលប៉ះពាល់នៃការអនុវត្តគោលនយោបាយ និងច្បាប់ផ្សេងៗ ព្រមទាំងបណ្ដឹងតវ៉ានានារបស់ប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលជាអង្គបោះឆ្នោតរបស់ព្រឹទ្ធសភាឱ្យបានទៀងទាត់ពេលវេលា និងជាក់ស្ដែង(Real Time) ដោយប្រើប្រាស់នូវបណ្ដាញសង្គម(Social Media) បណ្ដាញទំនាក់ទំនង(Social Network System) គេហទំព័រ និងបណ្ដាញសង្គមផ្ទាល់ខ្លួន(Twitter Facebook) ដើម្បីសម្របសម្រួលទំនាក់ទំនង និងប្រមូលធាតុចូលជាអតិបរិមាពីប្រជាពលរដ្ឋ និងក្រុមប្រជាពលរដ្ឋបែបចម្រុះប្រកបដោយភាពស្និទ្ធស្នាល និងភាតរភាព ព្រមទាំងរកវិធីដោះស្រាយជូនប្រជាពលរដ្ឋឱ្យបានល្អប្រសើរ។

IV-សេវាសភាអេឡិចត្រូនិក

ផ្អែកលើការស្រាវជ្រាវមួយរបស់ Papaloi & Gouscos (2010, p.107) ដោយយោងតាមមាតិកាសេវានៃគេហទំព័រសភានាពេលបច្ចុប្បន្ន អ្នកទទួលបានផលប្រយោជន៍ពីការចូលអានគេហទំព័រ រួមមាន៖ សភា សមាជិកសភា ប្រជាពលរដ្ឋ អ្នកសារព័ត៌មាន និងប្រព័ន្ធឃោសនា។ សេវាកម្មសភាអេឡិចត្រូនិកផ្ដោតលើទម្រង់ដូចខាងក្រោម៖

សភា ទៅ សភា (P2P) (Parliament to Parliament)	ការផ្លាស់ប្ដូរព័ត៌មានរវាងសភានិងសភាជាតម្រូវការចាំបាច់ក្នុងការចែករំលែកគ្នាទៅវិញទៅមក ជាពិសេសក្នុងក្របខ័ណ្ឌនៃសភាតំបន់ ឬលក្ខណៈពិសេសដោយឡែក ឧទាហរណ៍៖ ករណីទិន្នន័យ IPEX(www.ipex.eu)គឺជាប្រព័ន្ធគេហទំព័រទិន្នន័យមួយ ដែលត្រូវប្រើប្រាស់សម្រាប់ការចែករំលែកព័ត៌មានពីសភាថ្នាក់ជាតិទៅសភាអឺរ៉ុប។
សភាជាមួយសមាជិកសភា (P2MP) (Parliament-to-Members of Parliament)	សេវានេះ ពាក់ព័ន្ធការរៀបចំកម្មវិធីបច្ចេកវិទ្យាសម្រាប់ភ្ជាប់សភាជាមួយនឹងសមាជិកសភា ដែលអាចប្រើប្រាស់សម្រាប់សម្របសម្រួលការងារសភា ជាមួយប្រធានសភាតាមរយៈការប្រើប្រាស់កម្មវិធី ស្មាតហ្វូនចល័ត (Mobile Technology) វេបម៉ែល (Webmail) និងការទាញយកឯកសារច្បាប់ពីចម្ងាយ (Remote Access To Legislative Documents)
ប្រជាពលរដ្ឋជាមួយសភា (C2P) (Citizen-to-Parliament)	សេវានេះ ត្រូវផ្ដល់មធ្យោបាយជូនប្រជាពលរដ្ឋអាចទទួលបានព័ត៌មាន ដើម្បីទំនាក់ទំនងជាមួយសមាជិកសភា និងផ្ដល់ឱ្យប្រជាពលរដ្ឋអាចធ្វើការផ្ដល់យោបល់ត្រឡប់មកសមាជិកសភាវិញបាន។

សភាជាមួយប្រជាពលរដ្ឋ (P2C) (Parliament-to-Citizen)	សេវានេះត្រូវផ្តួចផ្តើមដោយសភាខ្លួនឯង ដោយធ្វើយ៉ាងណាទាក់ទាញចំណាប់អារម្មណ៍ និងការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងដំណើរការតាក់តែងច្បាប់ ជាពិសេសមុខងារនីតិកម្ម។ ការងារត្រួតពិនិត្យ និងអនុវត្តន៍ច្បាប់ក្នុងគណៈកម្មការជំនាញសភា ត្រូវឱ្យមានការចូលរួមពីប្រជាពលរដ្ឋ និងម្ចាស់ឆ្នោតបានចូលរួមក្នុងដំណើរការការងារនីតិកម្មរបស់សភា។
សភាជាមួយប្រព័ន្ធផ្សព្វផ្សាយ (P2Media) (Parliament-to-Media)	សេវាដែលបង្កើតឡើងដោយសភាសហភាពអឺរ៉ុប ក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយសម្រាប់សភាអឺរ៉ុប ដើម្បីផ្តល់នូវព័ត៌មានសំខាន់ៗជូនដល់អ្នកសារព័ត៌មានស្តីពី កម្មវិធីការងារគម្រោងព័ត៌មានសង្ខេប ឬការងារផ្សេងៗទៀតរបស់សភាអឺរ៉ុប។

ផ្អែកលើការងារស្រាវជ្រាវ និងវាយតម្លៃដោយអន្តរសភា ព្រមទាំងការអនុវត្តនៃសភានានា យើងអាចបន្ថែមសេវាកម្មមួយចំនួនដូចខាងក្រោម៖

គណៈកម្មការជំនាញជាមួយប្រជាពលរដ្ឋ (C2C) (Parliamentary Commission to Citizen)	សេវាកម្មដែលប្រើប្រាស់សម្រាប់ផ្សព្វផ្សាយ និងចែករំលែកព័ត៌មានទៅវិញទៅមករវាងគណៈកម្មការជំនាញជាមួយប្រជាពលរដ្ឋ ដូចជាសកម្មភាពការងារគណៈកម្មការ កិច្ចការនីតិកម្ម អត្ថបទច្បាប់ ឬសេចក្តីព្រាងច្បាប់ ឬការប្រមូលមតិយោបល់ផ្សេងៗរបស់ប្រជាពលរដ្ឋតាមរយៈ ការប្រើប្រាស់គេហទំព័រគណៈកម្មការ ថ្នាលឌីជីថល ឬប្រព័ន្ធបណ្តាញសង្គម (SNS)

V-វឌ្ឍនភាពបច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភា

១-បច្ចុប្បន្នភាពអគ្គលេខាធិការដ្ឋាន

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជាសេនាធិការរបស់ព្រឹទ្ធសភា ដែលមានតួនាទីទទួលខុសត្រូវរ៉ាប់រងការងាររដ្ឋបាល និងបច្ចេកទេសសម្រាប់ព្រឹទ្ធសភា ហើយមានអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរង ជាថ្នាក់ដឹកនាំ។ បច្ចុប្បន្ន អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាមានអគ្គាធិការដ្ឋាន និងអគ្គនាយកដ្ឋានចំនួនប្រាំ ដែលជាសេនាធិការរួមមាន៖ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី អគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ អគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ ព្រមទាំងអគ្គនាយកដ្ឋានស្រាវជ្រាវ ដើម្បីគាំទ្រដល់ព្រឹទ្ធសភាក្នុងការបំពេញមុខងារសំខាន់ៗ ប្រកបដោយប្រសិទ្ធភាព និងគុណភាពខ្ពស់។ ជាមួយគ្នានេះ

អគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ គឺជាសេនាធិការផ្ទាល់ដែលមានតួនាទីផ្តល់សេវាគាំទ្រលើកកម្ពស់ប្រសិទ្ធភាពមុខងារព្រឹទ្ធសភាតាមរយៈការផ្តល់សេវាការគ្រប់គ្រងផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងសាធារណៈពីខាងក្នុង-ក្រៅព្រឹទ្ធសភាឱ្យសាធារណជនស្គាល់ ដឹង យល់ពីសកម្មភាព និងកិត្យានុភាពរបស់ព្រឹទ្ធសភា និងមកទំនាក់ទំនងជាមួយព្រឹទ្ធសភា។ នៅក្នុងនោះផងដែរ នាយកដ្ឋានព័ត៌មានវិទ្យាចំណុះឱ្យអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈដែលជាអង្គភាពជំនាញទាក់ទងនឹងបច្ចេកវិទ្យាព័ត៌មានដែលមានតួនាទី គ្រប់គ្រង ថែទាំ អភិវឌ្ឍន៍ និងផ្សព្វផ្សាយបច្ចេកវិទ្យាទូរគមនាគមន៍របស់ព្រឹទ្ធសភា-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងពង្រឹងចំណេះដឹងព័ត៌មានវិទ្យាជូនមន្ត្រីអគ្គលេខាធិការដ្ឋាន-សមាជិកព្រឹទ្ធសភា។

២-ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា

ការផ្តល់វិភាគទាន និងកិច្ចគាំទ្រដ៏ថ្លៃថ្លារបស់អង្គការនីតិប្បញ្ញត្តិអន្តរជាតិ ជំនួយពីដៃគូអភិវឌ្ឍន៍សភា និងរដ្ឋាភិបាលនៃប្រទេសជាមិត្ត ព្រមទាំងអង្គការអន្តរជាតិនានា រួមផ្សំនឹងកិច្ចខិតខំប្រឹងប្រែង និងការវិនិយោគបន្ថែមផ្ទាល់ខ្លួនរបស់ព្រឹទ្ធសភា បានរួមគ្នាបង្កើតជាសមិទ្ធិផលលើការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់ព្រឹទ្ធសភា ដែលបាននឹងកំពុងប្រើប្រាស់ដោយសកម្មប្រកបដោយគុណភាព ប្រសិទ្ធភាព និងការទទួលខុសត្រូវ។

ជាការពិតណាស់ ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាគឺជាមូលដ្ឋាននៃការតភ្ជាប់បណ្តាញដែលធ្វើឱ្យឧបករណ៍អេឡិចត្រូនិកពីកន្លែងមួយទៅកន្លែងមួយអាចទំនាក់ទំនង និងឆ្លើយឆ្លងផ្ទេរទិន្នន័យឱ្យគ្នាទៅវិញទៅមក។ បច្ចុប្បន្នព្រឹទ្ធសភាមានបណ្តាញណែតវើកនៅក្នុងអគារ និងសាលប្រជុំផ្សេងៗនៅក្នុងបរិវេណព្រឹទ្ធសភា ព្រមទាំងនៅក្នុងអគារនីមួយៗមានបណ្តាញតភ្ជាប់ពីការិយាល័យមួយទៅការិយាល័យមួយ ពីអង្គភាពមួយទៅអង្គភាពមួយ តាមរយៈបណ្តាញស្នូលខ្សែកាបអុបទិច។ ព្រឹទ្ធសភាបានវិនិយោគបន្ថែមទៅលើការបំពាក់ប្រព័ន្ធការពារ(Firewall) ដែលមានសមត្ថភាពត្រួតពិនិត្យការពារប្រព័ន្ធផ្ទៃក្នុងពីការជ្រៀតជ្រែក និងត្រួតពិនិត្យគ្រប់គ្រងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត (NOC) នៅក្នុងអគារសេវើ(Server)របស់ព្រឹទ្ធសភា។ ហើយការតភ្ជាប់នេះបានផ្តល់លទ្ធភាពលើការប្រើប្រាស់ និងបែងចែកសេវាកម្មអ៊ីនធឺណិត ព្រមទាំងសេវាកម្មអេឡិចត្រូនិកមួយចំនួនផ្សេងៗទៀត។ ជាមួយគ្នានេះក្នុងឆ្នាំ២០២១ ទោះបីជាជួបនឹងការប្រឈមខាងផ្នែកសុខាភិបាលសាធារណៈនៃការរាតត្បាតនៃជំងឺកូវីដ១៩ ក៏ដោយ អគ្គលេខាធិការដ្ឋានបានកសាងអគារមជ្ឈមណ្ឌលព័ត៌មានវិទ្យាព្រឹទ្ធសភាចំនួនមួយខ្នងដែលមានកម្ពស់បីជាន់ ដើម្បីប្រើប្រាស់ជាទីកន្លែងសម្រាប់តម្កល់ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារកាន់តែល្អប្រសើរ និងមានសុវត្ថិភាពជាងមុន ក៏ដូចជាប្រើប្រាស់សម្រាប់ជាមជ្ឈមណ្ឌលបណ្តុះបណ្តាល និងចំណេះដឹងព័ត៌មានវិទ្យាជូនមន្ត្រីនៃអគ្គលេខាធិការដ្ឋាន ព្រមទាំងជាទីកន្លែងសម្រាប់បំពេញការងាររបស់មន្ត្រីបច្ចេកទេសព័ត៌មានវិទ្យានៃនាយកដ្ឋានព័ត៌មានវិទ្យាឱ្យមានលក្ខណៈកាន់តែល្អប្រសើរ និងមានផាសុកភាពមួយកម្រិតថែមទៀត។



គំរូតាង៖ បណ្តាញណែតវើកបច្ចុប្បន្នរបស់ព្រឹទ្ធសភា

៣-ឧបករណ៍អេឡិចត្រូនិក

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាមានទីកន្លែងធ្វើការសមរម្យ និងបានបំពាក់នូវគ្រឿងបរិក្ខារ សម្ភារៈ និងឧបករណ៍អេឡិចត្រូនិក មានដូចជា៖ កំព្យូទ័រយួរដៃ កំព្យូទ័រលើតុ អាយផេត(iPad) ម៉ាស៊ីនថតចម្លង និងម៉ាស៊ីនស្កេនឯកសារជាមួយនឹងការបំពាក់បណ្តាញអ៊ីនធឺណិតជូនសមាជិកព្រឹទ្ធសភា សម្រាប់ជាមធ្យោបាយបំពេញការងារប្រចាំថ្ងៃ។ ទោះបីជាយ៉ាងណាក៏ដោយ ឧបករណ៍ និងសម្ភារៈមួយចំនួនបានចាស់ទ្រុឌទ្រោម និងបានជួសជុលប្រើប្រាស់បន្តឱ្យអស់លទ្ធភាព និងសក្តានុពលសម្ភារៈទាំងនោះប្រកបដោយការទទួលខុសត្រូវ និងការយកចិត្តទុកដាក់ខ្ពស់ចំពោះនិរន្តរភាពការងាររបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

៤-សេវាកម្ម និងសុហ្វែរព័ត៌មានវិទ្យា

ក្នុងរយៈពេលកន្លងទៅសេវាកម្មឌីជីថលមួយចំនួនបានកំពុងដំណើរការ និងប្រើប្រាស់មានដូចជា កម្មវិធីគ្រប់គ្រងទិន្នន័យច្បាប់(Legal Database) គេហទំព័រព្រឹទ្ធសភា(Senate Website) កម្មវិធីគ្រប់គ្រងបណ្ណាល័យ(LMS) គេហទំព័ររបស់គណៈកម្មការជំនាញទាំង១០ព្រឹទ្ធសភា គេហទំព័រទិន្នន័យរបស់អង្គភាពមួយចំនួនចំណុះអគ្គលេខាធិការដ្ឋាន កម្មវិធីគ្រប់គ្រងថវិកា(Accounting System Program) កម្មវិធីគ្រប់គ្រងបុគ្គលិក(HRMS) កម្មវិធីគ្រប់គ្រងឯកសារតាមបណ្តាញ(NAS) កម្មវិធីគ្រប់គ្រងបណ្តាញ(NOC) កម្មវិធីសារអេឡិចត្រូនិកព្រឹទ្ធសភា(Email) កម្មវិធីទំនាក់ទំនងបណ្តាញសង្គម(Facebook, Telegram, and Line.) ប្រព័ន្ធសូឌីយូសម្រាប់សាលប្រជុំ(សាលប្រជុំពេញអង្គព្រឹទ្ធសភានិងសាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា) ប្រព័ន្ធប្រជុំពីចម្ងាយ តាមសាលប្រជុំនានារបស់ព្រឹទ្ធសភា(Zoom) ។

៥-កត្តាអំណោយផល និងការប្រឈម

ក.កត្តាអំណោយផល

ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយ កម្ពុជាជាប្រទេសដែលកំពុងមានសន្ទុះកំណើនសេដ្ឋកិច្ច-នយោបាយជាតិប្រកបដោយស្ថិរភាព សន្តិភាព និងវិបុលភាព។ កត្តានេះបានជះឥទ្ធិពលគ្របដណ្តប់យ៉ាងធំទៅដល់កំណើន និងភាពរីកចម្រើននៃបច្ចេកវិទ្យាព័ត៌មានទាំងកម្រិតមីក្រូ និងម៉ាក្រូរបស់ជាតិ។ ផ្អែកតាមការវាស់កម្រិតសន្ទស្សន៍រដ្ឋាភិបាលឌីជីថល (EGDI) ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយដោយនាយកដ្ឋានសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ (UN-DESA) បានបង្ហាញលទ្ធផលអំពីសញ្ញាណប្រកបដោយភាពវិជ្ជមានកម្រិតខ្ពស់ឆ្ពោះទៅជារាជរដ្ឋាភិបាលឌីជីថលកម្រិតជឿនលឿន ដោយផ្អែកលើកត្តាវិនិច្ឆ័យបីជាគោលៈ សេវាអនឡាញ (វិសាលភាព និងគុណភាព) ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ និងអត្រាអ្នកប្រើប្រាស់អ៊ីនធឺណិត។ នៅឆ្នាំ២០២០ ព្រះរាជាណាចក្រកម្ពុជាបានទទួលចំណាត់ថ្នាក់ទី១២៤ ក្នុងចំណោម១៩៣ប្រទេស កើនឡើងចំនួន២១ថ្នាក់ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៨។ ជាមួយនឹងលទ្ធផលនេះ កម្ពុជាបានដាក់ចេញនូវគោលនយោបាយថ្មីៗមួយចំនួនដើម្បីលើកកម្ពស់ និងជំរុញដំណើរការក្រោមមូលបទសំខាន់ឆ្ពោះទៅជាសេដ្ឋកិច្ចសង្គមឌីជីថលកម្ពុជា (ឆ្នាំ២០២១-២០៣៥) ព្រមទាំងកំពុងរៀបចំនូវគោលនយោបាយថ្មីៗដូចជា រាជរដ្ឋាភិបាលឌីជីថល និងគោលនយោបាយគាំទ្រជាបន្តបន្ទាប់ទៀត។ យើងអាចកត់សម្គាល់បានថាកត្តានេះជាសូចនាករនយោបាយដ៏សំខាន់មួយក្នុងការចូលរួមលើកកម្ពស់ទៅដល់ដំណើរការបច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភាអេឡិចត្រូនិកប្រកបដោយការទទួលខុសត្រូវ និងភាពច្បាស់លាស់។

ភាពអំណោយផលនៃកត្តាមនុស្ស ឬប្រជាសាស្ត្រ ដោយផ្អែកលើអត្រាប្រជាជនកម្ពុជាដែលមានអាយុក្រោម៣៥ឆ្នាំប្រមាណ៤០% អាចមានលទ្ធភាពខ្ពស់ចាប់យក និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានយ៉ាងសកម្ម ហើយយុវវ័យដែលជាកត្តាចលករយ៉ាងសំខាន់នៅក្នុងការចូលរួមយ៉ាងសកម្មនៅដំណើរការអភិវឌ្ឍជាតិ និងនយោបាយ។ កម្ពុជាបានទទួលនូវកត្តាអំណោយផលមួយទៀតតាមរយៈការប្រើប្រាស់អ៊ីនធឺណិតតាមរយៈការប្រើប្រាស់ឧបករណ៍ឆ្លាតវៃ (ទូរស័ព្ទ កំព្យូទ័រ និងឧបករណ៍ឆ្លាតវៃផ្សេងៗ)ផ្អែកលើទិន្នន័យអ្នកប្រើប្រាស់អ៊ីនធឺណិតជាមួយឧបករណ៍ឆ្លាតវៃចំនួន១៦,៣៣លានគ្រឿង ស្មើនឹង៩៨,៩៥% ដោយក្នុងនោះបើគិតអំពីអ្នកចុះឈ្មោះប្រើប្រាស់សេវាទូរស័ព្ទចល័តមានចំនួន២០,៨២លានលេខ ស្មើនឹង១២៦,១៩%នៃចំនួនប្រជាជនសរុប។ កត្តាមួយទៀត វត្តមាននៃសេវាកម្មអនឡាញទាំងកម្រិតសេវាសាធារណៈ និងឯកជនបានកើនឡើងជាបន្តបន្ទាប់រួមផ្សំភាពបត់បែនទីផ្សារ និងទម្រង់ការរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាដែលមានលក្ខណៈទំនើប ដូចនេះយើងមានសុទិដ្ឋិនិយមថាសេវាកម្មឬសុហ្វែរថ្មីៗរបស់ព្រឹទ្ធសភាអេឡិចត្រូនិកនឹងមានការចូលរួមប្រើប្រាស់ និងទទួលយកប្រកបដោយលទ្ធផលវិជ្ជមាន ដើម្បីប្រើប្រាស់ជាឧត្តមប្រយោជន៍ដល់ប្រជាពលរដ្ឋ ស្ថាប័ន និងជាតិទាំងមូល។

ខ.ការប្រឈម

កង្វះខាតគោលនយោបាយដែលទាន់សម័យ និងសមស្របនឹងបរិការណ៍ថ្មី ព្រឹទ្ធសភាបានតាក់តែងគោលនយោបាយបច្ចេកវិទ្យាព័ត៌មានចំនួន០២លើក ក្រោមរូបភាពជាផែនការមេស្តីពី «ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានសម្រាប់សភាកម្ពុជានៅឆ្នាំ២០០៣» តាមរយៈការគាំទ្របច្ចេកទេសដោយអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា

(UNDP) ហើយផែនការមេឆ្នាំ២០០៣នេះត្រូវបានកែសម្រួលទៅជាផែនការមេអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានសម្រាប់ព្រឹទ្ធសភានៅឆ្នាំ២០០៦ និងបន្តអនុវត្តន៍មកដល់សព្វថ្ងៃ។

កង្វះខាតហេដ្ឋារចនាសម្ព័ន្ធរឹងមាំ ហេដ្ឋារចនាសម្ព័ន្ធនាពេលបច្ចុប្បន្នបានផ្តល់ការអនុគ្រោះទៅដល់ការប្រើប្រាស់មូលដ្ឋានសម្រាប់អ្នកប្រើប្រាស់ដូចជា ការងាររដ្ឋបាលទូទៅ និងការប្រើប្រាស់អ៊ីនធឺណិត ។ ដោយឡែកហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានគោលមិនអនុគ្រោះដល់ការបង្ហោះ និងគ្រប់គ្រងទៅលើសេវាកម្មដូចជា គេហទំព័រផ្លូវការរបស់ព្រឹទ្ធសភា គេហទំព័របណ្ណាល័យអេឡិចត្រូនិក ទិន្នន័យច្បាប់ និងសេវាកម្មផ្សេងៗដែលត្រូវភ្ជាប់ជាមួយនឹងអ៊ីនធឺណិត ឬហៅថាសេវាកម្មអនឡាញ (Online Services) ហើយដោយជំនួសមកវិញព្រឹទ្ធសភាត្រូវប្រើប្រាស់សេវាកម្មជួលជាមួយវិស័យឯកជន (ក្រុមហ៊ុនISP ក្នុងស្រុក និងក្រៅប្រទេស) ដែលជាហានិភ័យយ៉ាងខ្លាំងទៅដល់ការបាត់បង់ឯកសារ ភាពឯកជន និងភាពសម្ងាត់របស់ស្ថាប័ន (Loss Privacy & Confidentiality)។

ការវិនិយោគ ការវិវឌ្ឍរបស់ស្ថាប័នបានដើរយ៉ាងលឿនពីនីតិកាលមួយទៅនីតិកាលមួយ ហើយបច្ចេកវិទ្យាព័ត៌មានជាចំណែកដែលចាំបាច់មានវត្តមាននៅក្នុងដំណើរការរីកចម្រើននេះ។ ថវិកាជាតិដែលផ្តល់ទៅលើការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននៅមានកម្រិតបើប្រៀបធៀបទៅនឹងសេចក្តីត្រូវការរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។ ថវិកាជាតិដែលផ្តល់សម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននៅមានកម្រិតប្រហាក់ប្រហែល១%(មួយភាគរយ) នៃថវិកាព្រឹទ្ធសភាប្រចាំឆ្នាំទាំងមូល ជាពិសេសក្នុងដំណាក់កាលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ព្រឹទ្ធសភាបានចូលរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាលតាមរយៈការធ្វើវិចារណកម្មថវិកាប្រចាំឆ្នាំ ដើម្បីចូលរួមនៅក្នុងដំណាក់កាលដ៏លំបាកនេះ។

ការរីកចម្រើននៃបច្ចេកវិទ្យាព័ត៌មានយ៉ាងលឿន និងវិវឌ្ឍន៍ឥតឈប់ឈរ ភាពរីកចម្រើននៃបច្ចេកវិទ្យាព័ត៌មានដូចជាបច្ចេកវិទ្យាទូរគមនាគមន៍ជំនាន់ទី៥ (5G) បញ្ញាសិប្បនិម្មិត(AI) បណ្តាញ (Block chain) វត្ថុអ៊ីនធឺណិត (IOT) និងបញ្ហាសន្តិសុខព័ត៌មានដែលបានបង្កឱកាស និងការគំរាមកំហែងដល់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់ព្រឹទ្ធសភា ជាពិសេសការវិវឌ្ឍរបស់ស្ថាប័ន និងកម្រិតអ្នកប្រើប្រាស់មួយចំនួននៅមានភាពយឺតយ៉ាវឬនៅមានកម្រិតមូលដ្ឋានទាបនៅឡើយ។

ខ្វះធនធានមនុស្ស កត្តាធនធានមនុស្សជាកត្តាចម្បងសម្រាប់ការជំរុញ និងលើកកម្ពស់ទៅដល់ការកសាង និងរៀបចំសេវាកម្មបច្ចេកវិទ្យាព័ត៌មាន ជាពិសេសការងារផ្សព្វផ្សាយ និងការបញ្ជ្រាបការយល់ដឹងអំពីបច្ចេកវិទ្យាព័ត៌មានទៅដល់អតិថិជនផ្ទៃក្នុង និងក្រៅស្ថាប័ន។ បច្ចុប្បន្នអ្នកបច្ចេកទេសព័ត៌មានវិទ្យារបស់ព្រឹទ្ធសភា ដែលបម្រើលើវិស័យនេះនៅមានកម្រិតឯកទេសទាបនៅឡើយទាក់ទងនឹងជំនាញចាំបាច់មួយចំនួនមានជាអាទិ៍ៈ ជំនាញអភិវឌ្ឍន៍កម្មវិធី (Programming) ជំនាញគ្រប់គ្រងទិន្នន័យ (Database Specialist) ជំនាញគ្រប់គ្រងបណ្តាញ (Networking Specialist) ជំនាញសន្តិសុខព័ត៌មាន(Cyber Security Specialist) ជំនាញបង្កើតមាតិកាឬផ្សព្វផ្សាយ (Content Creator & Media) ជំនាញគ្រប់គ្រង និងទីផ្សារឌីជីថល (PM and Digital Marketing) ..។ល។ មន្ត្រីបច្ចេកវិទ្យាព័ត៌មាននៅខ្វះបទពិសោធន៍និងការយល់ដឹងអំពីបច្ចេកវិទ្យាព័ត៌មាននៅក្នុងការងារសភាដែលជាកិច្ចការដ៏មានសារៈសំខាន់នៅក្នុងការផ្សារភ្ជាប់បច្ចេកវិទ្យាព័ត៌មាននិងការងារព្រឹទ្ធសភាឱ្យមានលក្ខណៈស៊ីជម្រៅ និងចំគោលដៅផងដែរ។

VI-ផែនការមេបរិវត្តកម្មព្រឹទ្ធសភាអេឡិចត្រូនិក

១-ទស្សនវិស័យ

យោងតាមចក្ខុវិស័យរបស់ព្រឹទ្ធសភាក្នុង(២០២១-២០៣០) ព្រឹទ្ធសភាបានដាក់ចេញនូវគោលនយោបាយ និងសកម្មភាពឆ្ពោះទៅអនុវត្តន៍ការងារជាប្រព័ន្ធនៃសភាទំនើប ដោយឈរលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- **ភាពតំណាង** : ខាងសង្គម និងនយោបាយប្រកបដោយបរិយាបន្នរបស់ប្រជាជាតិទាំងមូលដែលចម្រុះគ្នា ហើយធានាដល់ភាពតំណាងដោយស្មើភាពគ្នា និងដោយតុល្យភាពខាងយេនឌ័រសម្រាប់សមាជិកព្រឹទ្ធសភាទាំងអស់។
- **តម្លាភាព** : ដោយបើកចំហទំនាក់ទំនងចំពោះប្រជាពលរដ្ឋទាំងអស់តាមរយៈប្រព័ន្ធព័ត៌មាន និងបណ្ដាញសង្គម និងមានតម្លាភាពនៅក្នុងការចាត់ចែងកិច្ចការសព្វសារពើរបស់ព្រឹទ្ធសភា។
- **ភាពចូលដិតបាន** : ដោយចេះលើកទឹកចិត្តឱ្យប្រជាពលរដ្ឋ ជាពិសេសសាធារណជន យុវជន កុមារ សមាគម អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន អាចចូលរួមបានក្នុងដំណើរការការងាររបស់សភា។
- **គណនេយ្យភាព** : សមាជិកព្រឹទ្ធសភាត្រូវរាយការណ៍ដោយទៀងទាត់ឱ្យម្ចាស់ឆ្នោតបានដឹងអំពីរបៀប និងលទ្ធផលដែលបានបំពេញក្នុងអាណត្តិរបស់ខ្លួន ដើម្បីបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងប្រទេសជាតិ និងអំពីសុចរិតភាពជាឧត្តមគតិ និងឆន្ទៈប្ដូរផ្ដាច់របស់ខ្លួន។
- ការចាត់តាំងត្រូវស្របតាមគុណតម្លៃប្រជាធិបតេយ្យ ហើយបំពេញបានល្អនូវមុខងារនីតិកម្ម តំណាង និងត្រួតពិនិត្យរបស់សភា ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋទាំងមូល។

ស្របតាមទស្សនវិស័យប្រកបដោយប្រាកដនិយម និងសុទិដ្ឋិនិយមខាងលើ ផែនការមេស្ដីពីបរិវត្តកម្មព្រឹទ្ធសភាអេឡិចត្រូនិក បានកំណត់ថា «**ទស្សនវិស័យរបស់ព្រឹទ្ធសភាសំដៅទំនើបនីយកម្មការងារព្រឹទ្ធសភាដោយប្រើប្រាស់សក្ដានុពល និងឧត្តមភាពនៃបច្ចេកវិទ្យាព័ត៌មាន ដើម្បីឆ្ពោះទៅជាសភាទំនើបមួយប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល ភាពបើកចំហ និងនវានុវត្តន៍** »។



គំនូសតាងស្តីពីទស្សនវិស័យរបស់ព្រឹទ្ធសភា ២០២២-២០៣០

២-បេសកកម្ម

ជាមួយនឹងទស្សនវិស័យនៃផែនការមេខាងលើ ព្រឹទ្ធសភាបានដាក់ចេញនូវបេសកកម្ម គឺ « ការបង្កើតព្រឹទ្ធសភាអេឡិចត្រូនិកមួយដែលមានលក្ខណៈ **រឹងមាំ បើកចំហ និងនវានុវត្តន៍** ដើម្បីចូលរួមអភិវឌ្ឍន៍សង្គមជាតិប្រកបដោយ នីតិរដ្ឋ ស៊ីវិល័យ វិបុលភាព និងវឌ្ឍនភាព ក្រោមដំបូលនៃសុខសន្តិភាព»។

៣-គោលបំណង

ដើម្បីឆ្លើយតបទៅនឹងទស្សនវិស័យ និងបេសកកម្មខាងលើនេះ ផែនការមេមានគោលបំណងសំខាន់ៗ មានដូចខាងក្រោម៖

- ពង្រឹងពង្រីកការតភ្ជាប់ជាមួយសង្គមជាតិតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដែលមានប្រសិទ្ធភាព រហ័ស សុវត្ថិភាព និងជឿជាក់បាន។
- ពង្រឹងពង្រីកការធ្វើបរិវត្តកម្មឌីជីថលទៅលើមុខងារទាំងបីរបស់ព្រឹទ្ធសភាប្រកបដោយប្រសិទ្ធភាព និងនវានុវត្តន៍ស្របតាមនីតិរដ្ឋ និងបរិបទនៃលទ្ធិប្រជាធិបតេយ្យ។
- ពង្រឹងពង្រីកកិត្យានុភាពស្ថាប័ន និងជាតិ តាមរយៈគុណតម្លៃនៃសភាប្រជាធិបតេយ្យ។

៤- សារៈសំខាន់នៃផែនការមេ

ផែនការមេស្តីពីបរិវត្តកម្មព្រឹទ្ធសភាអេឡិចត្រូនិកមានសារៈសំខាន់ដូចខាងក្រោម៖

- កំណត់អំពីត្រីវិស័យ ផែនការ សកម្មភាព និងធនធានអនុវត្តន៍ ដែលមានលក្ខណៈប្រទាក់ក្រឡា និងតាមលំដាប់លំដោយ ផ្អែកលើការប្រមូលព័ត៌មាន និងវិភាគតម្រូវការរបស់ស្ថាប័ន ព្រមទាំងប្រជាពលរដ្ឋ។
- កំណត់អំពីសក្តានុពល និងឧត្តមភាពនៃបច្ចេកវិទ្យាព័ត៌មាន ដើម្បីបង្រួមគម្លាតរវាងព្រឹទ្ធសភា និងប្រជាពលរដ្ឋឱ្យបានជាអតិបរមា និងជាជំហានៗ។
- ពង្រឹងពង្រីកផលិតផលបច្ចេកវិទ្យាព័ត៌មានដែលសមស្របនឹងតម្រូវការព្រឹទ្ធសភា និងសង្គមជាតិ។
- ពង្រឹងពង្រីកការដ្ឋាននិងការអនុវត្តគម្រោងបច្ចេកវិទ្យាព័ត៌មានសម្រាប់ព្រឹទ្ធសភាដោយឈរលើគោលការណ៍ «ប្រសិទ្ធភាព ប្រសិទ្ធផល និងការសន្សំសំចៃ»។
- ពង្រឹងពង្រីកចំណេះដឹងបច្ចេកវិទ្យាព័ត៌មានជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការ និងលើកកម្ពស់ភាពជាដៃគូជាមួយគ្រប់ភាគីពាក់ព័ន្ធរបស់ព្រឹទ្ធសភាលើការងារបច្ចេកវិទ្យាព័ត៌មាន។

៥-គោលដៅជាអាទិភាព

ដើម្បីសម្រេចនូវទស្សនវិស័យ បេសកកម្ម និងគោលបំណងខាងលើ ផែនការមេនេះមានគោលដៅអាទិភាពចំនួនប្រាំមួយមានដូចខាងក្រោម៖

គោលដៅអាទិភាពទី១-ពង្រឹងពង្រីកហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាប្រកបដោយភាពរឹងមាំ និងមានលក្ខណៈជាប្រព័ន្ធពពក (CLOUD)។

គោលដៅអាទិភាពទី២-ពង្រឹងពង្រីកផលិតភាពការងារ និងសេវាកម្មបច្ចេកវិទ្យាព័ត៌មាន ដើម្បីគាំទ្រមុខងារស្នូលទាំងបីរបស់ព្រឹទ្ធសភាប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈវៃឆ្លាត។

គោលដៅអាទិភាពទី៣-ពង្រឹងពង្រីកការគ្រប់គ្រង និងការទទួលយកគម្រោងបច្ចេកវិទ្យាពត៌មានសម្រាប់ព្រឹទ្ធសភា។

គោលដៅអាទិភាពទី៤-ពង្រឹងពង្រីកទំនាក់ទំនងសាធារណៈ និងព័ត៌មានដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន។

គោលដៅអាទិភាពទី៥-ការកសាង និងអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្សប្រកបដោយលក្ខណៈឈ្លាសវៃ ។

គោលដៅអាទិភាពទី៦-ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការភាពជាដៃគូរវាងព្រឹទ្ធសភា និងដៃគូពាក់ព័ន្ធដើម្បីពង្រឹងពង្រីកកិច្ចអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភា។

គោលដៅអាទិភាពទី១ ពង្រឹងពង្រីកហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាប្រកបដោយភាពរឹងមាំ និងមានលក្ខណៈជាប្រព័ន្ធពពក (CLOUD)

គោលដៅនេះមានគោលបំណងសំខាន់ ដើម្បីដាក់ចេញនូវទិសដៅការងារពង្រឹងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាគោល (Core System Infrastructure) និងពង្រឹងពង្រីកប្រព័ន្ធភាពធន (Service Delivery System) ស្របតាមទិសដៅឆ្ពោះទៅជាប្រព័ន្ធពពក(Cloud Computing) ប្រកបដោយភាពរឹងមាំ និងសុវត្ថិភាព។ ប្រព័ន្ធពពករបស់ព្រឹទ្ធសភាត្រូវរៀបចំដោយឈរលើមូលដ្ឋាន **១.មូលដ្ឋានគោលតែមួយ**(The Once-Only Principle) មានន័យថាជាគោលការណ៍ដែលត្រូវអនុវត្តជាប្រព័ន្ធរួម ដោយមានទិន្នន័យប្រព័ន្ធតែមួយសម្រាប់ព្រឹទ្ធសភា **២.គោលការណ៍អន្តរប្រតិបត្តិការជាមួយប្រព័ន្ធអេកូឡូស៊ីតែមួយ**(Interoperability as an Ecosystem) ជាគោលការណ៍មួយដែលបច្ចេកវិទ្យាឌីជីថលរបស់ព្រឹទ្ធសភាត្រូវអនុលោមតាមស្តង់ដារប្រព័ន្ធតែមួយ ហើយប្រព័ន្ធនេះមានលទ្ធភាពឆ្លើយតបនឹងប្រព័ន្ធរួមរបស់ជាតិផង និងអន្តរជាតិផង ដោយសារទិន្នន័យអាចត្រូវប្រើប្រាស់ជាពីរប្រភេទ គឺផ្ទៃក្នុងថ្នាក់ជាតិ (ក្រោមក្របខ័ណ្ឌរាជរដ្ឋាភិបាលឌីជីថលឬថ្នាល ថ.ផ.ទ) និងមានលក្ខណៈអន្តរជាតិ (ក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអន្តរជាតិលើការងារផ្លាស់ប្តូរទិន្នន័យ)។

សកម្មភាពទី១-ការរៀបចំប្រព័ន្ធពពកមួយដែលមានប្រសិទ្ធភាព និរន្តភាព និងសុវត្ថិភាព

ព្រឹទ្ធសភាត្រូវរៀបចំកសាងមជ្ឈមណ្ឌលទិន្នន័យមួយដែលមានលក្ខណៈស្តង់ដារនិងសុវត្ថិភាពខ្ពស់ ជាពិសេសការគោរព និងអនុវត្តន៍នូវស្តង់ដារសុវត្ថិភាព និងមានមធ្យោបាយឧបករណ៍គ្រប់គ្រាន់ដោយឈរលើមូលដ្ឋានស្តង់ដារដូចជា៖ ISO 27001 ឬ ISO 20000-1ជាដើម។ មជ្ឈមណ្ឌលទិន្នន័យចាំបាច់ត្រូវមានប្រព័ន្ធគាំទ្រ(Faculty) ដូចជា៖ ប្រព័ន្ធអគ្គិសនីច្បាស់លាស់ (Power Supply & UPS) ប្រព័ន្ធរំសាយកម្តៅ (Cooling System) ធ្នើរសុវត្ថិភាព (Rack Floors) ប្រព័ន្ធការពារអគ្គីភ័យ(Fire Control) ប្រព័ន្ធទ្វារសុវត្ថិភាព(Security Door) ប្រព័ន្ធឌីជីថលកាមេរ៉ាសុវត្ថិភាព ព្រមទាំងប្រព័ន្ធសុហ្វែរទប់ស្កាត់ការវាយប្រហារ(IPS) ប្រព័ន្ធសុហ្វែរតាមដាន (Network Monitoring Software) និងប្រព័ន្ធសុហ្វែរការពារឯកសារ (End Points Software) ប្រព័ន្ធរក្សាទិន្នន័យ និងគ្រប់គ្រងហានិភ័យ (Recovery Data System) ប្រព័ន្ធផ្ទុកទិន្នន័យ (File Server) និងប្រព័ន្ធផ្សេងៗ...។ល។

សកម្មភាពទី២-ការពង្រឹងបណ្តាញផ្ទៃក្នុង(Campus Infrastructure) និងសេវាសន្តិសុខព័ត៌មានផ្ទៃក្នុងព្រឹទ្ធសភា (Core Internal Security)

ព្រឹទ្ធសភាត្រូវរៀបចំប្រព័ន្ធបណ្តាញក្នុងអគារធ្វើការសម្រាប់សមាជិក មន្ត្រី និងសេវាកម្មសាធារណជនដូចជា បណ្ណាល័យ បណ្ណសារដ្ឋាន ឱ្យមានលក្ខណៈស្តង់ដារដោយឈរលើគោលការណ៍បួនរួមមាន៖ ១. ធានាលំហូរទិន្នន័យត្រឹមត្រូវនិងរហ័ស ២.ភាពពង្រីកបាន(Scalability) ៣.គុណភាពសេវាកម្ម(QOS) និង៤.សន្តិសុខ(Security)។ បន្ថែមពីនេះ ប្រព័ន្ធបណ្តាញអ៊ីនធឺណិតអត់ខ្សែ(Wireless System) និងការគ្រប់គ្រងឧបករណ៍អេឡិចត្រូនិកផ្សេងៗ ដូចជា៖ កុំព្យូទ័រ (លើតុ-យួរដៃ)ឧបករណ៍បន្ទាប់បន្សំ (បោះពុម្ព និងថតចម្លង) ឧបករណ៍វៃឆ្លាត (ទូរស័ព្ទដៃ-អាយផេត) រួមទាំងត្រូវមានប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណ និងប្រព័ន្ធត្រួតពិនិត្យ ជាពិសេសត្រូវឈានទៅអនុវត្តន៍នូវគោលការណ៍សន្តិសុខផ្ទៃក្នុង និងគោលការណ៍អ្នកប្រើប្រាស់ឧបករណ៍ផ្ទាល់ខ្លួន (BYOD)។

សកម្មភាពទី៣-កសាងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធពពកឯកជនរបស់ព្រឹទ្ធសភា

ការរៀបចំប្រព័ន្ធពពកឯកជនរបស់ព្រឹទ្ធសភាត្រូវចាប់ផ្តើមចេញពីការរៀបចំ ១.សេវាកម្មពពក(Software as a Service) ២.ថ្នាលឌីជីថល(Platform as a service) ៣.សេវាពពកហេដ្ឋារចនាសម្ព័ន្ធ (Infrastructure as a Service) សម្រាប់ដំណើរការធ្វើបរិវត្តកម្មឌីជីថលរបស់ព្រឹទ្ធសភា។ ការរៀបចំសេវាកម្មពពកនេះ(SaaS) ផ្តោតសំខាន់ទៅកសាងហេដ្ឋារចនាសម្ព័ន្ធគោលពពកគាំទ្រដោយផ្តល់អាទិភាពសំខាន់ទៅដល់មុខងារទាំងបីរបស់ព្រឹទ្ធសភា (នីតិកម្ម តំណាង និងត្រួតពិនិត្យ) ដើម្បីពង្រឹងពង្រីកប្រតិបត្តិការ និងផលិតភាពការងាររបស់ព្រឹទ្ធសភាប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។ ថ្នាលឌីជីថល (Platform as a Service) ត្រូវសិក្សារៀបចំគោលការណ៍ផ្តោតទៅលើការប្រើប្រាស់ទិន្នន័យរួមតែមួយដោយផ្តួចផ្តើមដោយក្រុមការងារបច្ចេកវិទ្យាព័ត៌មានព្រឹទ្ធសភា និងអង្គភាពចំណុះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ហើយជាពិសេសថ្នាលឌីជីថលត្រូវរៀបចំតាមទម្រង់ ក្របខ័ណ្ឌ និងបទដ្ឋានសុហ្វែរ ដែលដាក់ចេញដោយអាជ្ញាធរ និងក្រសួងជំនាញបច្ចេកវិទ្យាព័ត៌មាន(ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍)។

សកម្មភាពទី៤-ការកសាងរៀបចំប្រព័ន្ធអត្តសញ្ញាណឌីជីថល និងប្រព័ន្ធហត្ថលេខាឌីជីថលរបស់ព្រឹទ្ធសភា

ដើម្បីធ្វើសង្គតិភាព និងអន្តរកម្មទំនាក់ទំនងជាមួយប្រព័ន្ធថ្នាលផ្លាស់ប្តូរទិន្នន័យ (ថ.ផ.ទ) និងប្រព័ន្ធផ្សេងៗក្រោមកិច្ចសហប្រតិបត្តិការនៃការចែករំលែកឯកសារ។

សកម្មភាពទី៥-ការពង្រឹងពង្រីកមូលធនមនុស្ស (Human Capital)

ការបង្កើនសមត្ថភាពធនធានមនុស្សរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានជាសកម្មភាពមួយដែលមានសារៈសំខាន់ និងត្រូវបានកំណត់ជាកត្តាជោគជ័យនៃការអនុវត្តផែនការមេនេះប្រកបដោយការទទួលខុសត្រូវ និងប្រាកដនិយម។ សកម្មភាពនេះបានដាក់ចេញបន្តការយកចិត្តទុកដាក់ទៅលើការកសាងឯកទេស និងជំនាញរបស់មន្ត្រីបច្ចេកទេសព័ត៌មានរបស់ព្រឹទ្ធសភាឈរលើមូលដ្ឋាន«រក្សាចាស់-បង្កើតថ្មី» ដោយរក្សាបរិមាណមន្ត្រីជំនាញបច្ចេកទេស និងលើកកម្ពស់គុណភាពជំនាញថ្មីៗ ដូចជា៖ ជំនាញហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា និងពពក (Network Infrastructure & Cloud Computing) ជំនាញសន្តិសុខព័ត៌មាន(Cyber Security Specialist) ជំនាញគ្រប់គ្រងគម្រោងឌីជីថល(PM) ជំនាញសរសេរកម្មវិធី និងអភិវឌ្ឍន៍សុហ្វែរ(Programing Specialist) ជំនាញវិភាគទិន្នន័យ និងគ្រប់គ្រង(Database Specialist) ជំនាញទីផ្សារ និងយុទ្ធសាស្ត្រឌីជីថល(Digital Marketing & Strategy Specialist) ជំនាញរដ្ឋបាលឌីជីថល(IT Administration Specialist) ជំនាញសិល្បៈឌីជីថល(Media & Digital Creator) ជំនាញផ្តល់សេវាព័ត៌មានវិទ្យា(IT Supports) ជំនាញបណ្ណាល័យ បណ្ណសារដ្ឋាន និងការស្រាវជ្រាវ ព្រមទាំងជំនាញផ្សេងៗទៀត។

សកម្មភាពទី៦-ពង្រឹងពង្រីកការផ្គត់ផ្គង់បណ្តាញអ៊ីនធឺណិត (Internet Supply)

សកម្មភាពនេះបានដាក់ចេញជាការឆ្លើយតបទៅលើតម្រូវការនៃការប្រើប្រាស់អ៊ីនធឺណិតរបស់អ្នកប្រើប្រាស់ និងការធានានិរន្តរភាពនៃសេវាកម្មរបស់ព្រឹទ្ធសភានានា ដែលត្រូវបានបង្កើត និងបង្កើនជាបន្តបន្ទាប់។

គោលដៅអាទិភាពទី២ ពង្រឹងពង្រីកផលិតភាពការងារ និងសេវាកម្មបច្ចេកវិទ្យាព័ត៌មាន ដើម្បីគាំទ្រមុខងារស្នូលទាំងបីរបស់ព្រឹទ្ធសភាប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈវៃឆ្លាត។

ទំនាក់ទំនងរវាងគោលដៅអាទិភាពទី១ និងទី២ជាទំនាក់ទំនងដែលមិនអាចខ្វះគ្នាបាន។ គោលដៅអាទិភាពទី២ នេះមានគោលបំណងសំខាន់ ដើម្បីកំណត់សកម្មភាពនៅក្នុងការពង្រឹងផលិតភាពការងារតាមរយៈការបញ្ចូល បច្ចេកវិទ្យាព័ត៌មានទៅក្នុងប្រតិបត្តិការរដ្ឋបាល បច្ចេកទេស និងការងារសព្វសារពើរបស់ព្រឹទ្ធសភា ដើម្បីគាំទ្រដល់ការបំពេញមុខងារស្នូលទាំងបីរបស់ព្រឹទ្ធសភាប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលជូនសង្គមជាតិ។

សកម្មភាពទី១-ពង្រឹងពង្រីកផលិតភាពលើមុខងារនីតិកម្មរបស់ព្រឹទ្ធសភាដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន

ក.ការពង្រឹង និងពង្រីកទ្រព្យសម្បត្តិឯកសាររបស់ស្ថាប័នឱ្យបានគង់វង្ស និងមានរបៀបរៀបរយដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល

ក.១. បន្តការរៀបចំ និងទំនើបនីយកម្មសុហ្វែរគ្រប់គ្រងបណ្ណាល័យអេឡិចត្រូនិក (E-Library, ILIS)។

ក.២. រៀបចំនិងបង្កើតសុហ្វែរគ្រប់គ្រងឯកសារបណ្ណសារដ្ឋានអេឡិចត្រូនិក (E-Archive)។

ក.៣. កសាង និងរៀបចំទិន្នន័យឯកសារស្រាវជ្រាវប្រកបដោយលក្ខណៈឈ្លាសវៃ និងទំនើប (Digital Repository)។

ខ.ធ្វើនិយ័តកម្មការងារនីតិកម្មព្រឹទ្ធសភាឈានទៅជាការងារនីតិកម្មបែបប្រព័ន្ធអេឡិចត្រូនិករបស់សភាមួយស្របតាមស្តង់ដារនិងប្រសិទ្ធភាពខ្ពស់

ខ.១. បន្តរៀបចំ និងកែលម្អសុហ្វែរគ្រប់គ្រងទិន្នន័យច្បាប់ឱ្យមានលក្ខណៈងាយស្រួល និងគ្រប់ជ្រុងជ្រោយ។

ខ.២. រៀបចំ និងបង្កើនប្រព័ន្ធទិន្នន័យរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ដែលមានលក្ខណៈស្តង់ដារ និងប្រមូលផ្តុំនូវសារៈតានៃដំណើរការរៀបចំរដ្ឋធម្មនុញ្ញតាមដំណាក់កាលនីមួយៗ។

ខ.៣.រៀបចំសុហ្វែរគ្រប់គ្រងដំណើរការត្រួតពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់។

ខ.៤.បន្តរៀបចំសុហ្វែរគ្រប់គ្រងការផ្តល់យោបល់របស់សមាជិកលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។

ខ.៥.រៀបចំសុហ្វែរគ្រប់គ្រងរបាយការណ៍ពិស្តារ និងសង្ខេបសម្រាប់កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ សម័យប្រជុំពេញអង្គព្រឹទ្ធសភា។

គ.បន្តកសាងមធ្យោបាយឌីជីថល ដើម្បីលើកកម្ពស់ការងារនីតិកម្មប្រកបដោយប្រសិទ្ធភាព និងគុណភាពសំដៅឆ្លើយតបនឹងគោលបំណងរួមមាន ១.សាលប្រជុំព្រឹទ្ធសភាត្រូវមានលក្ខណៈទំនើប ២.កាត់បន្ថយការប្រើប្រាស់ក្រដាស និងគាំពារបរិស្ថានខ្ពស់ និង៣.ពង្រឹងប្រសិទ្ធភាពនៃកិច្ចប្រជុំ ហើយជាពិសេសការកសាងទំនើបនីយកម្មសាលប្រជុំពេញអង្គ សាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសាលប្រជុំផ្សេងៗរបស់ព្រឹទ្ធសភាមានលក្ខណៈទំនើប និងគាំពារដល់បរិស្ថាន (ការប្រើប្រាស់ឯកសារក្រដាសសូន្យត្រឹមឆ្នាំ២០៣០)

គ.១.កសាង និងរៀបចំនូវសុហ្វែរគ្រប់គ្រងសាលប្រជុំទំនើប (Paper Less System)

គ.២.កសាង និងរៀបចំប្រព័ន្ធប្រជុំពីចម្ងាយសម្រាប់កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ប្រជុំពេញអង្គព្រឹទ្ធសភា និងកិច្ចប្រជុំនានារបស់ព្រឹទ្ធសភា

គ.៣.កសាង និងរៀបចំប្រព័ន្ធស្នូឌីយូដោយស្វ័យប្រវត្តិសម្រាប់សាលប្រជុំនានារបស់ព្រឹទ្ធសភា

គ.៤.កសាង និងរៀបចំប្រព័ន្ធបំប្លែងសំឡេងទៅជាអក្សរ(OCR) ដោយប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត(AI)

គ.៥.កសាង និងរៀបចំសុហ្វែរបកប្រែភាសាចម្រុះ ព្រមទាំងសុហ្វែរ និងកម្មវិធីឌីជីថលផ្សេង ដើម្បីគាំទ្រដល់ការងារនីតិកម្មរបស់ព្រឹទ្ធសភា

ឃ. កសាង និងរៀបចំប្រព័ន្ធសម្រាប់ព្រឹទ្ធសភាក្នុងកាលៈទេសៈប្រធានសក្តិ ដើម្បីធានាប្រក្រតីភាពដំណើរការស្ថាប័ន

ឃ.១.រៀបចំប្រព័ន្ធប្រជុំពីចម្ងាយដោយប្រើប្រាស់ថ្នាល និងសុហ្វែរមួយប្រកបដោយភាពជឿជាក់ជាមួយនឹងទំនុកចិត្តខ្ពស់

ឃ.២.ការរៀបចំនូវប្រព័ន្ធបោះឆ្នោត ការអនុម័តឌីជីថល និងអត្តសញ្ញាណកម្មឌីជីថលដោយផ្តោតលើភាពងាយស្រួល និងសុវត្ថិភាព។

សកម្មភាពទី២-ពង្រឹងពង្រីកផលិតភាពលើមុខងារតាមដានការអនុវត្តច្បាប់របស់ព្រឹទ្ធសភាដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន

ចំពោះមុខងារតាមដានការអនុវត្តច្បាប់របស់ព្រឹទ្ធសភា គោលដៅទី២នេះបានដាក់ចេញនូវសកម្មភាព ដើម្បីផ្តោតលើការប្រមូលព័ត៌មាន និងទិន្នន័យពីក្រសួង-ស្ថាប័នចំណុះឱ្យរាជរដ្ឋាភិបាលដែលជាការងារអាទិភាព។ ផ្អែកលើភាពរីកចម្រើននៃបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាលក្រោមក្របខ័ណ្ឌសង្គមសេដ្ឋកិច្ចឌីជីថល និងរាជរដ្ឋាភិបាលឌីជីថល(Digital Royal Government) ដែលកំពុងមានដំណើរការ និងបន្តអភិវឌ្ឍន៍ជាបណ្តើរៗ។ កត្តានេះផ្តល់ឱកាស និងលទ្ធភាពដល់កិច្ចអភិវឌ្ឍរបស់ព្រឹទ្ធសភាលើការងារបច្ចេកវិទ្យាព័ត៌មាន។ ដើម្បីឆ្លើយតបនឹងគោលដៅនេះសកម្មភាពមួយចំនួនត្រូវបានដាក់ចេញដូចខាងក្រោម៖

ក.ការកសាង និងធ្វើសង្គតិភាពជាមួយប្រព័ន្ធគ្រប់គ្រងទិន្នន័យជាមួយបណ្តាក្រសួងពាក់ព័ន្ធជាពិសេសការចូលរួមអនុវត្តន៍អនុក្រឹត្យស្តីពី «ថ្នាលផ្លាស់ប្តូរទិន្នន័យ CamDX» របស់រាជរដ្ឋាភិបាលតាមរយៈប្រព័ន្ធផ្ទាល់(VPN) និងប្រព័ន្ធអ៊ីនធឺណិត ក៏ដូចជាគោលនយោបាយផ្សេងៗសំដៅដើម្បីធ្វើអន្តរកម្មទិន្នន័យជាមួយក្រសួង ស្ថាប័នសាធារណៈ និងដៃគូផ្សេងៗទាំងវិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ។

ខ.កសាង និងរៀបចំសុហ្វែរស្ថិតិទិន្នន័យថវិកាជាតិសម្រាប់ព្រឹទ្ធសភា ដើម្បីផ្តល់លទ្ធភាពដល់ការវិភាគ និងស្រាវជ្រាវជាជំនួយស្មារតី ស្តីពី ថវិកាជាតិ នៅដំណាក់កាលមុនដំណាច់ឆ្នាំនីមួយៗតាមរយៈនាយកដ្ឋានថវិកាសការរបស់ព្រឹទ្ធសភា ដើម្បីផ្តល់ជាជំនួយស្មារតីបច្ចេកទេសដល់ថ្នាក់ដឹកនាំ ព្រឹទ្ធសភា គណៈកម្មការជំនាញទាំង១០ និងសមាជិកព្រឹទ្ធសភា។

សកម្មភាពទី៣-ការពង្រឹងពង្រីកផលិតភាពលើមុខងារតំណាងរបស់ព្រឹទ្ធសភាដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន

សកម្មភាពទី៣បានដាក់ចេញនូវការពង្រីកសេវាកម្មលើមុខងារតំណាង ដើម្បីពង្រឹងពង្រីកកិត្យានុភាពស្ថាប័នជាមួយនឹងធន្ទះមោះមុតដោយផ្តោតលើគោលការណ៍នីតិរដ្ឋ ប្រជាធិបតេយ្យ និងតម្លាភាពជូនប្រជាពលរដ្ឋតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានដូចខាងក្រោម៖

- **ក.**ការបន្តពង្រឹងពង្រីកគេហទំព័រព្រឹទ្ធសភាប្រកបដោយលក្ខណៈចម្រុះ និងសម្បូរបែប ជាពិសេសបន្តការអនុវត្តដោយយកចិត្តទុកដាក់តាមស្តង់ដារនិងបទដ្ឋានបច្ចេកទេសកម្រិតជាតិ-អន្តរជាតិ
- **ខ.**ការពង្រឹងពង្រីកការងារផ្សព្វផ្សាយ ដោយប្រើប្រាស់ឧត្តមភាព និងប្រជាប្រិយភាពនៃសេវាអ៊ីនធឺណិតដូចជា ការបង្កើតនូវវិទ្យុ និងទូរទស្សន៍អនឡាញ តាមរយៈឧបករណ៍វៃឆ្លាត កំព្យូទ័រ និងទូរស័ព្ទដៃវៃឆ្លាត
- **គ.**ការរៀបចំឡើងនូវសុហ្វែរគ្រប់គ្រងការទទួលពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ សុហ្វែរពិភាក្សាពីចម្ងាយ (e-discussion) និងសុហ្វែរផ្សេងៗ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) ទិន្នន័យទូលំទូលាយ (Big Data) និងបច្ចេកវិទ្យាផ្សេងៗ ។
- **ឃ.**លើកកម្ពស់មុខងារតំណាងរបស់ស្ថាប័នព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភាឱ្យកាន់តែប្រសើរនៅក្នុងការដោះស្រាយការលំបាករបស់ប្រជាពលរដ្ឋបានទាន់ពេល ប្រសិទ្ធភាព និងឆាប់រហ័សដោយប្រើប្រាស់កម្មវិធីបណ្តាញសង្គម និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗសម្រាប់ព្រឹទ្ធសភា សមាជិក និងរចនាសម្ព័ន្ធនយោបាយនានារបស់ព្រឹទ្ធសភា។

គោលដៅអាទិភាពទី៣ ការពង្រីកការគ្រប់គ្រង និងការទទួលយកគម្រោងបច្ចេកវិទ្យាព័ត៌មានសម្រាប់ព្រឹទ្ធសភា

គោលដៅទី៣នេះមានគោលបំណងសំខាន់ ដើម្បីដាក់ចេញនូវសកម្មភាពចម្បងៗសំដៅធានានិរន្តភាពនិងកិច្ចដំណើរការបច្ចេកវិទ្យាព័ត៌មានប្រកបដោយត្រីវិស័យត្រឹមត្រូវ និងច្បាស់លាស់។ ដើម្បីបន្តការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានប្រកបដោយចីរភាព គឺទាមទារនូវការពង្រឹងការងារគ្រប់គ្រង ការធ្វើផែនការ ព្រមទាំងការអនុវត្តគម្រោងព័ត៌មានវិទ្យាឈរលើមូលដ្ឋានតម្រូវការរបស់អតិថិជន និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងការសន្សំសំចៃខ្ពស់។ គោលដៅនេះបានកំណត់ការពង្រឹងសមត្ថភាពធនធានមនុស្ស និងយន្តការផ្សេងៗដែលមានសារៈសំខាន់នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការអភិវឌ្ឍ និងការអនុវត្តគម្រោងបច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភាឱ្យទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់។ បន្ថែមពីនេះ ការយល់ដឹង និងការផ្សព្វផ្សាយត្រូវអនុវត្តន៍ជាប្រចាំតាមរយៈការបណ្តុះបណ្តាល សិក្ខាសាលា ព្រមទាំងមធ្យោបាយផ្សេងៗដើម្បីបើកទូលំទូលាយឱ្យគ្រប់ភាគីបានចូលរួមនៅក្នុងដំណើរការកសាងបច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភា ប្រកបដោយភាពចម្រុះ និងប្រសិទ្ធភាព។ សកម្មភាពចាំបាច់មួយចំនួនត្រូវបានដាក់ចេញដូចខាងក្រោម៖

សកម្មភាពទី១-ពង្រឹងសមត្ថភាពធនធានមនុស្សលើការគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន និងការកសាងផែនការ

ក.ពង្រឹងសមត្ថភាពការងារគ្រប់គ្រង និងការកសាងផែនការរបស់មន្ត្រីបច្ចេកទេសព័ត៌មានវិទ្យារបស់ព្រឹទ្ធសភា

ខ.បង្កើតយន្តការ និងទម្រង់ចែករំលែកផ្សេងៗ ដើម្បីសិក្សាអំពីការអនុវត្ត និងបទពិសោធន៍ស្តីពីការអនុវត្តគម្រោងព័ត៌មានវិទ្យាព្រឹទ្ធសភា

សកម្មភាពទី២-ពង្រឹងយន្តការ និងរចនាសម្ព័ន្ធការគ្រប់គ្រងដឹកនាំការដ្ឋានបច្ចេកវិទ្យាព័ត៌មាន និងការផ្តួចផ្តើមគំនិតថ្មីៗ

ក.បង្កើតគណៈកម្មការបច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភា ដើម្បីដឹកនាំ និងសម្រេចលើការងារបច្ចេកវិទ្យាព័ត៌មាន។

ខ.បង្កើតក្រុមការងារបច្ចេកទេសពិសេស ដើម្បីអនុវត្តន៍គម្រោងព័ត៌មានវិទ្យាសម្រាប់ព្រឹទ្ធសភាតាមឆ្នាំនីមួយៗ។

គ.បង្កើតមជ្ឈមណ្ឌលព័ត៌មានវិទ្យាព្រឹទ្ធសភា ដើម្បីជំរុញការងារការអនុវត្តនៃបច្ចេកវិទ្យាព័ត៌មានប្រកបដោយគុណភាព និងប្រសិទ្ធភាព។

ឃ.រៀបចំ និងកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងរបស់នាយកដ្ឋានព័ត៌មានវិទ្យា ដើម្បីឆ្លើយតបនឹងតម្រូវការតាមដំណាក់កាលនីមួយៗ។

ង.ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការទំនាក់ទំនងជាមួយនឹងនាយកដ្ឋាន និងអគ្គនាយកដ្ឋានព័ត៌មានវិទ្យានៃរដ្ឋសភាដើម្បីកសាង និងអភិវឌ្ឍសេវាកម្មរួមសម្រាប់សភាកម្ពុជា។

ច.សិក្សា កសាង និងវាយតម្លៃជាប្រចាំអំពីតម្រូវការ និងសំណូមពររួមរបស់ព្រឹទ្ធសភាលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន។

ឆ.កសាងផែនការសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភាប្រចាំឆ្នាំ ប្រចាំ៣ឆ្នាំ និងប្រចាំនីតិកាលនីមួយៗ។

ជ.ការកសាងបទដ្ឋាន និងគោលនយោបាយ ឆ្លើយតបនឹងផលិតផលបច្ចេកវិទ្យាព័ត៌មាន និងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភា ។

គោលដៅអាទិភាពទី៤ ពង្រឹងពង្រីកទំនាក់ទំនងសាធារណៈ និងព័ត៌មានដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន

គោលបំណងសំខាន់នៅក្នុងគោលដៅនេះ ដើម្បីពង្រឹងពង្រីកការយល់ដឹងជូនដល់សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលជាម្ចាស់ឆ្នោតរបស់សមាជិកព្រឹទ្ធសភា និងប្រជាពលរដ្ឋទូទៅទាក់ទងកិច្ចការងារសព្វសារពើរបស់ព្រឹទ្ធសភា ដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងគោលដៅកាត់បន្ថយគម្លាតរវាងព្រឹទ្ធសភាជាមួយនឹងម្ចាស់ឆ្នោត និងប្រជាពលរដ្ឋ។ សកម្មភាពមួយចំនួនត្រូវបានដាក់ចេញដូចខាងក្រោម ៖

សកម្មភាពទី១-ការរៀបចំកម្មវិធីបណ្តុះបណ្តាលអនឡាញស្តីពីព្រឹទ្ធសភាតាមរយៈអ៊ីនធឺណិតគេហទំព័រ សុហ្វែរទូរស័ព្ទវៃឆ្លាត និងវីដេអូផ្សេងៗ

សកម្មភាពទី២-កសាងនូវកម្មវិធី និងសុហ្វែរគ្រប់គ្រងដំណើរទស្សនកិច្ចព្រឹទ្ធសភារបស់សាធារណជន

សកម្មភាពទី៣-កសាង និងរៀបចំកម្មវិធីបណ្តុះបណ្តាលចល័តតាមភូមិភាគទាំង៨ (Mobility Training) ដើម្បីចូលរួមធ្វើអក្ខរកម្មឌីជីថលជូនដល់សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់

សកម្មភាពទី៤-រៀបចំកម្មវិធីប្រជុំពេញអង្គព្រឹទ្ធសភាដោយប្រើប្រាស់បច្ចេកវិទ្យាសិប្បនិម្មិត (VDR)

សកម្មភាពទី៥-រៀបចំគេហទំព័រសារមន្ទីរ និងពិព័រណ៍រូបភាពឌីជីថលព្រឹទ្ធសភា (Senate Digital Gallery-Database)

សកម្មភាពទី៦-ការបង្កើតមជ្ឈមណ្ឌលបច្ចេកវិទ្យាព័ត៌មានសម្រាប់បណ្តុះបណ្តាលមន្ត្រីនៃអគ្គលេខាធិការ-ដ្ឋានព្រឹទ្ធសភា ក្រុមប្រឹក្សាឃុំ-សង្កាត់ និងសាធារណជន រួមទាំងកម្មវិធីផ្សេងៗទាក់ទងនឹងបច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភា។

សកម្មភាពទី៧-ការពង្រឹងទំនាក់ទំនងដោយប្រើប្រាស់ប្រព័ន្ធប្រៃសណីយ៍ និងប្រព័ន្ធទូរគមនាគមន៍ផ្សេងៗ ដើម្បីឱ្យប្រជាពលរដ្ឋងាយស្រួលទំនាក់ទំនងដូចជា មជ្ឈមណ្ឌលទទួលព័ត៌មាន (Call Center) ប្រព័ន្ធកត់ត្រាការទំនាក់ទំនង និងមធ្យោបាយទំនាក់ទំនងសង្គមផ្សេងៗ។

គោលដៅអាទិភាពទី៥ ការកសាង និងអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្សប្រកបដោយលក្ខណៈឈ្លាសវៃ

គោលបំណងសំខាន់នៅក្នុងគោលដៅនេះបានដាក់ចេញនូវសកម្មភាពសំខាន់ៗ ដើម្បីឆ្លើយតបនឹងការកសាងធនធានមនុស្សសមស្របទៅនឹងទស្សនវិស័យឆ្ពោះទៅជាសភាទំនើប ឬព្រឹទ្ធសភាអេឡិចត្រូនិក(២០២២-២០៣០) ជាពិសេសផ្តោតទៅលើមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានគ្រប់ជាន់ថ្នាក់ និងសមាជិកព្រឹទ្ធសភាក្រោមទស្សន «មន្ត្រីវៃឆ្លាត និងសមាជិកព្រឹទ្ធសភាវៃឆ្លាត»។ សកម្មភាពមួយចំនួនត្រូវដាក់ចេញដូចខាងក្រោមៈ

សកម្មភាពទី១-បញ្ជ្រាបការយល់ដឹង និងចំណេះដឹងបច្ចេកវិទ្យាព័ត៌មានជូនសមាជិកព្រឹទ្ធសភា តាមរយៈការធ្វើសិក្ខាសាលា បណ្តុះបណ្តាល និងកម្មវិធីផ្សេងៗ ព្រមទាំងលើកកម្ពស់ការសិក្សាស្រាវជ្រាវលើការងារបច្ចេកវិទ្យាតាមរយៈការចងក្រងឯកសារនិងអត្ថបទស្រាវជ្រាវផ្សេងៗ ដើម្បីជាជំនួយស្មារតីដល់សមាជិកព្រឹទ្ធសភា។

សកម្មភាពទី២-កសាងក្របខ័ណ្ឌ និងស្តង់ដារនៃការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថលជូនមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

សកម្មភាពទី៣-ពង្រឹងពង្រីកសមត្ថភាពមន្ត្រីរបស់អគ្គលេខាធិការដ្ឋានតាមរយៈការបណ្តុះបណ្តាលជំនាញបច្ចេកវិទ្យាឌីជីថលដោយក្រសួង ស្ថាប័នជំនាញ វិទ្យាស្ថាន មជ្ឈមណ្ឌល និងដៃគូផ្សេងៗ ស្របតាមតម្រូវការរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

សកម្មភាពទី៤-ពង្រឹងពង្រីកសមត្ថភាពការបណ្តុះបណ្តាលផ្ទៃក្នុង តាមរយៈការកសាងសមត្ថភាពគ្រូបង្គោល និងកម្មវិធីឌីជីថលផ្សេងៗ។

សកម្មភាពទី៥-រៀបចំកម្មវិធីតម្រង់ទិស ផ្សព្វផ្សាយ និងការកសាងគោលនយោបាយលើកទឹកចិត្តដល់ការលើកកម្ពស់សមត្ថភាពរបស់មន្ត្រីនៃអគ្គលេខាធិការដ្ឋានពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាន។

សកម្មភាពទី៦-ពង្រឹងពង្រីកសមត្ថភាពឌីជីថល និងការធ្វើនវានុវត្តន៍ដល់ជួរអ្នកដឹកនាំតាមអង្គភាព ចំណុះអគ្គលេខាធិការដ្ឋាន។

សកម្មភាពទី៧-បង្កើតសុហ្វែរការងាររដ្ឋបាល (E-Admin) សុហ្វែរការងារជាក្រុម(E-Team)និងសុហ្វែរគ្រប់គ្រងផែនការអង្គភាព(E-Planning) និងប្រព័ន្ធឌីជីថលផ្សេងៗ ដើម្បីលើកកម្ពស់គុណភាពការងារអង្គភាពចំណុះអគ្គលេខាធិការដ្ឋាន និងពង្រឹងប្រសិទ្ធភាពការងារជាក្រុមរបស់មន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

សកម្មភាពទី៨-បង្កើតកម្មវិធីសុហ្វែរ កម្មវិធីគ្រប់គ្រងការបណ្តុះបណ្តាល សុហ្វែរបង្រៀនពីចម្ងាយ និងគេហទំព័រទិន្នន័យស្រាវជ្រាវទាក់ទងនឹងបច្ចេកវិទ្យាព័ត៌មាន។

សកម្មភាពទី៩-ពង្រឹងពង្រីកវប្បធម៌រដ្ឋបាលឌីជីថល និងអក្ខរកម្មឌីជីថលតាមរយៈសិក្ខាសាលា និងកម្មវិធីផ្សេងៗ។

គោលដៅអាទិភាពទី៦ ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការ ភាពជាដៃគូរវាងព្រឹទ្ធសភា និងដៃគូពាក់ព័ន្ធ ដើម្បីពង្រឹងពង្រីកការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភា

គោលដៅនេះបានកំណត់អំពីការពង្រឹងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូលើជំនាញបច្ចេកវិទ្យាព័ត៌មានរវាងព្រឹទ្ធសភាជាមួយក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ដោយមានគោលបំណងអភិវឌ្ឍន៍រួមលើការងារបច្ចេកទេស ការអភិវឌ្ឍធនធានមនុស្ស និងកសាងជំនាញឯកទេសផ្សេងៗ ប្រកបដោយនិរន្តភាព និងនវានុវត្តន៍។ សកម្មភាពមួយចំនួន ត្រូវបានដាក់ចេញដើម្បីពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការលើការងារស្រាវជ្រាវ (R&D)ជាមួយមជ្ឈដ្ឋានស្រាវជ្រាវ សំដៅការអភិវឌ្ឍ និងការធ្វើនវានុវត្តន៍បច្ចេកវិទ្យាព័ត៌មានសម្រាប់ព្រឹទ្ធសភាមានជាអាទិ៍ មជ្ឈមណ្ឌលស្រាវជ្រាវ និងបច្ចេកវិទ្យាព័ត៌មាន សាកលវិទ្យាល័យ អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធបច្ចេកវិទ្យាព័ត៌មាន អ្នកស្រាវជ្រាវ និងក្រុមបញ្ញវន្ត។ កិច្ចសហប្រតិបត្តិការអន្តរជាតិលើការងារបច្ចេកវិទ្យាព័ត៌មាន ដោយបន្តផ្តោតទៅលើការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការ ផ្លាស់ប្តូរបទពិសោធន៍លើទិដ្ឋភាពបច្ចេកទេសការអភិវឌ្ឍធនធាន និងការអនុវត្តគម្រោងបច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភាជាមួយបណ្តាសភានានា តាមរយៈដំណើរទស្សនកិច្ចសិក្សា សិក្ខាសាលាអន្តរជាតិ និងកិច្ចការស្រាវជ្រាវផ្សេងៗ។ កិច្ចសហប្រតិបត្តិការអន្តរជាតិក៏បានផ្តោតទៅលើការពង្រឹងពង្រីកនៃការផ្លាស់ប្តូរទិន្នន័យជាមួយនឹងបណ្តាសភានានា ក្នុងក្របខ័ណ្ឌអាស៊ាន-អាស៊ី និងបណ្តាទ្វីបនានា ជាពិសេសការផ្តោតដោយយកចិត្តទុកដាក់ទៅលើការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌបច្ចេកទេសកិច្ចការបណ្ណាល័យ និងបណ្ណសារដ្ឋានមានជាអាទិ៍ បណ្ណាល័យ បណ្ណសារដ្ឋាន (សភា-សាធារណៈ) របស់បណ្តាប្រទេសនានា មជ្ឈមណ្ឌលស្រាវជ្រាវ អន្តរជាតិអង្គការអន្តរជាតិនិងមជ្ឈមណ្ឌលឯកជនលើការងារទិន្នន័យ(Online Journal) ដោយសំដៅរួមបង្កើនមូលធនឯកសារឱ្យមានលក្ខណៈសម្បូរបែបសម្រាប់កិច្ចការស្រាវជ្រាវ និងការងារនីតិកម្មរបស់ព្រឹទ្ធសភាក៏ដូចជាបង្កើតនូវកាលានុវត្តភាពលើកិច្ចការផ្សព្វផ្សាយនូវព័ត៌មាន និងទិន្នន័យរបស់ព្រឹទ្ធសភាទៅដល់ពិភពលោកផងដែរ។

សកម្មភាពចម្បងៗមួយចំនួនត្រូវបានដាក់ចេញមានជាអាទិ៍ដូចខាងក្រោម៖

សកម្មភាពទី១- ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរជាតិ វិស័យឯកជន មជ្ឈមណ្ឌលស្រាវជ្រាវ សាកលវិទ្យាល័យ និងអ្នកជំនាញ ពាក់ព័ន្ធជាមួយនឹងបច្ចេកវិទ្យាព័ត៌មាន ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងសហការនៅក្នុងការអនុវត្តគម្រោងបច្ចេកវិទ្យាព័ត៌មាន ការសិក្សាស្រាវជ្រាវ ព្រមទាំងការធ្វើនវានុវត្តន៍សម្រាប់ព្រឹទ្ធសភា។

សកម្មភាពទី២- ធ្វើសមាហរណកម្មទិន្នន័យរបស់ព្រឹទ្ធសភា និងរដ្ឋសភា ជាមួយនឹងបណ្តាសភានានា និងអង្គការអន្តរជាតិ ដើម្បីការផ្លាស់ប្តូរទិន្នន័យទៅវិញទៅមក។

សកម្មភាពទី៣- បន្តកិច្ចសហប្រតិបត្តិការជាមួយបណ្តាសភាជាមិត្ត អង្គការអន្តរជាតិ អង្គទូត និងដៃគូ ដើម្បីផ្តល់ការគាំទ្រ ដល់ការអភិវឌ្ឍធនធានមនុស្ស និងជំនួយបច្ចេកទេសផ្សេងៗ។

សកម្មភាពទី៤- បន្តពង្រឹងពង្រីកការសិក្សាស្រាវជ្រាវទៅលើការអនុវត្តល្អៗនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននៅតាមបណ្តាសភានានា និងអង្គការអន្តរជាតិទាក់ទងនឹងការងារសភា(IPU AIPA APF..។ល។)។

សកម្មភាពទី៥-បង្កើតអេឡិចត្រូនិកផនថល ដើម្បីចែករំលែកនូវធនធានឯកសារជាមួយដៃគូជាតិ-អន្តរជាតិទៅវិញទៅមក(E-portal & Open Data)។

សកម្មភាពទី៦- បង្កើត និងចូលរួមសហការរៀបចំសិក្ខាសាលាថ្នាក់តំបន់ និងអន្តរជាតិលើការងារអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មានព្រមទាំងបទពិសោធន៍ផ្សេងៗ ដែលមានប្រយោជន៍សម្រាប់សភាលើការងារបច្ចេកវិទ្យាព័ត៌មានកម្រិតតំបន់។

សកម្មភាពទី៧-ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការលើការងារផ្លាស់ប្តូរទិន្នន័យក្នុងក្របខ័ណ្ឌសភាតំបន់ ពិភពលោកកិច្ចការ បណ្ណាល័យ បណ្ណសារដ្ឋាន (ជាតិ-អន្តរជាតិ) និងក្របខ័ណ្ឌទ្វេភាគី-ពហុភាគីផ្សេងៗ។

សកម្មភាពទី៨- ពង្រឹងពង្រីកកិច្ចការស្រាវជ្រាវរួមគ្នារវាងព្រឹទ្ធសភា និងបណ្តាសភានានាក្នុងក្របខ័ណ្ឌប្រទេសអាស៊ានទាក់ទងនឹងបច្ចេកវិទ្យាព័ត៌មាន និងកិច្ចការសភា។

VII-យន្តការដឹកនាំ សម្របសម្រួល និងអនុវត្តន៍ផែនការមេ

១.យន្តការស្ថាប័នសម្រាប់សម្របសម្រួល និងអនុវត្តន៍

ផែនការមេស្តីពីបរិវត្តកម្មឌីជីថលរបស់ព្រឹទ្ធសភាត្រូវបានតាក់តែងឡើងដោយបានកំណត់អំពីត្រីវិស័យផែនការសកម្មភាព និងធនធានអនុវត្តន៍ ដែលមានលក្ខណៈប្រទាក់ក្រឡា និងតាមលំដាប់លំដោយ ផ្អែកលើការប្រមូលព័ត៌មាន និងការវិភាគអំពីតម្រូវការរបស់ព្រឹទ្ធសភា ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធ។ នៅក្នុងគោលបំណងដើម្បីសម្រេចផែនការនេះឱ្យទទួលបាននូវជោគជ័យប្រកបដោយភាពប្រាកដនិយម និងភាពច្បាស់លាស់។ ផែនការមេនេះចាំបាច់មានវត្តមាននៃតួអង្គសំខាន់ៗដូចជា ១.គណៈកម្មការបច្ចេកវិទ្យាព័ត៌មានព្រឹទ្ធសភា ដែលមានតួនាទីសំខាន់ក្នុងការសម្របសម្រួល ដឹកនាំ តាមដាន និងវាយតម្លៃអំពីផែនការមេនេះ ជាពិសេស សម្របសម្រួល និង

ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជំនាញព័ត៌មានវិទ្យារបស់ជាតិ-អន្តរជាតិ ព្រមទាំងបណ្តាសភានានា ២.ក្រុមការងារបច្ចេកទេសពិសេស ដែលមានតួនាទី និងភារកិច្ចសំខាន់សម្រាប់ការអនុវត្តគម្រោងបច្ចេកវិទ្យាព័ត៌មាន ៣.មជ្ឈមណ្ឌលព័ត៌មានវិទ្យាព្រឹទ្ធសភាដែលមានតួនាទីសំខាន់សម្រាប់សម្របសម្រួល ផែនការមេ ធ្វើនវានុវត្តន៍ និងលើកកម្ពស់បច្ចេកវិទ្យាព័ត៌មាន ៤.នាយកដ្ឋានព័ត៌មានវិទ្យាដែលមានតួនាទីសំខាន់សម្រាប់ផ្តល់នូវធនធានមនុស្ស និងបច្ចេកទេស ដើម្បីសម្រេចបាននូវការអនុវត្តគម្រោងបច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភា និងកិច្ចសហការជាមួយដៃគូជាតិ-អន្តរជាតិ។

ក. គណៈកម្មការបច្ចេកវិទ្យាព័ត៌មានព្រឹទ្ធសភា

គណៈកម្មការបច្ចេកវិទ្យាព័ត៌មានព្រឹទ្ធសភា គឺជាសេនាធិការជូនដល់ព្រឹទ្ធសភាទទួលបន្ទុកការងារជំរុញបរិវត្តកម្មឌីជីថលរបស់ព្រឹទ្ធសភា តាមរយៈការលើកកម្ពស់ការអនុវត្តនូវសកម្មភាពការងាររបស់ផែនការមេស្តីពីបរិវត្តកម្មឌីជីថលរបស់ព្រឹទ្ធសភាឱ្យទទួលបានជោគជ័យ និងសម្រេចដោយផ្លែផ្កា ស្របនឹងទស្សនវិស័យឆ្ពោះទៅជាសភាទំនើបនៅឆ្នាំ២០៣០។ គណៈកម្មការបច្ចេកវិទ្យាព័ត៌មានព្រឹទ្ធសភាដឹកនាំ ដោយថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងមានសមាសភាពសមាជិកដែលជាថ្នាក់ដឹកនាំរបស់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។ គណៈកម្មការនេះមានតួនាទី ដឹកនាំ សម្របសម្រួល ជំរុញ តាមដាន និងវាយតម្លៃការអនុវត្តផែនការមេមានជាអាទិ៍ គោលនយោបាយ យុទ្ធសាស្ត្រ វិធានការ ស្តង់ដារបច្ចេកទេស និងផែនការសកម្មភាពទាក់ទងនឹងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភា។ គណៈកម្មការនេះត្រូវទទួលសំណើគម្រោង និងផែនការរបស់អង្គភាពចំណុះអគ្គលេខាធិការដ្ឋាន ដើម្បីត្រួតពិនិត្យលក្ខណៈសម្បត្តិ បច្ចេកទេស និងហិរញ្ញវត្ថុ មុននឹងបញ្ចូលទៅក្នុងគម្រោងអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភាប្រចាំឆ្នាំ។ គម្រោងអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មានត្រូវបានបែងចែកជាបីប្រភេទ ១.គម្រោងវិនិយោគ (គម្រោងស្ថិតនៅក្រោមក្រសួងជំនាញរបស់គម្រោងរាជរដ្ឋាភិបាលឌីជីថល) ២.គម្រោងអភិវឌ្ឍន៍ក្រោមគម្រោងថវិការបស់ព្រឹទ្ធសភាប្រចាំឆ្នាំនីមួយៗ ៣.គម្រោងកិច្ចសហប្រតិបត្តិការជាតិ-អន្តរជាតិជាមួយនឹងដៃគូរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋាន។ គណៈកម្មការនេះមានសេនាធិការរដ្ឋបាល និងបច្ចេកទេស ដោយមជ្ឈមណ្ឌលព័ត៌មានវិទ្យា និងមានជំនួយការបច្ចេកទេសដោយនាយកដ្ឋានព័ត៌មានវិទ្យានៃអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ។

ខ.ក្រុមការងារបច្ចេកទេសពិសេស

ក្រុមការងារបច្ចេកទេសពិសេសមានតួនាទីអនុវត្តន៍នូវសកម្មភាព និងផែនការជាក់ស្តែងរបស់ផែនការមេស្តីពីបរិវត្តកម្មឌីជីថលរបស់ព្រឹទ្ធសភា ដែលបានកំណត់ដោយគណៈកម្មការបច្ចេកវិទ្យាព័ត៌មានព្រឹទ្ធសភា។ ក្រុមការងារនេះមានសមាសភាពប្រធានមួយរូប និងអនុប្រធានមួយរូបមកពីមជ្ឈមណ្ឌលព័ត៌មានវិទ្យាព្រឹទ្ធសភា នាយកដ្ឋានព័ត៌មានវិទ្យា ព្រមទាំងអង្គភាពពាក់ព័ន្ធផ្ទាល់នឹងគម្រោងបច្ចេកវិទ្យាព័ត៌មានដែលត្រូវអនុវត្តន៍នៅក្នុងឆ្នាំនីមួយៗ។ សមាសភាពសមាជិកសំខាន់ៗ ដែលមានពាក់ព័ន្ធនៅក្នុងគម្រោងបច្ចេកវិទ្យាព័ត៌មានដូចជា មន្ត្រីបច្ចេកទេសព័ត៌មានវិទ្យា មន្ត្រីជំនាញរបស់អង្គភាពម្ចាស់គម្រោង។ អ្នកប្រើប្រាស់ និងអ្នកទទួលសេវាព័ត៌មានវិទ្យាគួរលើកទឹកចិត្តឱ្យចូលរួមដើម្បីប្រមូលធាតុចូលឱ្យបានគ្រប់គ្រាន់។ ក្រុមការងារត្រូវចូលរួមសហការអនុវត្តន៍នូវគម្រោងបច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភា ដើម្បីឱ្យទទួលបាននូវលទ្ធផលល្អ និងទទួលបានជោគជ័យ។

គ.មជ្ឈមណ្ឌលព័ត៌មានវិទ្យាព្រឹទ្ធសភា

មជ្ឈមណ្ឌលព័ត៌មានវិទ្យាព្រឹទ្ធសភា ជារចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលមានតួនាទីសំខាន់ៗឆ្លើយតបនឹងសេចក្តីត្រូវការរបស់ផែនការមេស្តីពីបរិវត្តកម្មឌីជីថលរបស់ព្រឹទ្ធសភា និងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភា សម្រាប់ទាំងកម្រិតជាតិ-អន្តរជាតិ។ ការបង្កើតនូវមជ្ឈមណ្ឌលនេះមាន គោលបំណងសំខាន់ៗ ចំនួនបួន ១.ចូលរួមពង្រឹងតួនាទីមុខងាររបស់ព្រឹទ្ធសភាតាមរយៈការជំរុញ និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ២.សម្របសម្រួលការអនុវត្តសកម្មភាពនានាក្នុងផែនការមេស្តីពីបរិវត្តកម្មឌីជីថលរបស់ព្រឹទ្ធសភា ៣.ចូលរួមលើកកម្ពស់ការងារទំនាក់ទំនងសាធារណៈ និងព័ត៌មានរបស់ព្រឹទ្ធសភាដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ៤.ចូលរួមលើកកម្ពស់ស្មារតីកិច្ចសហប្រតិបត្តិការសភាក្នុងការងារបច្ចេកវិទ្យាព័ត៌មាន ជាពិសេសពង្រឹងពង្រីកតួនាទីរបស់ព្រឹទ្ធសភាកម្ពុជាចូលរួមក្នុងដំណើរការទំនើបនីយកម្មបច្ចេកវិទ្យាព័ត៌មាន របស់សភាតំបន់-អន្តរជាតិឆ្ពោះទៅរកភាពប្រសើរឡើងនៃតម្លាភាព គណនេយ្យភាព ការចូលរួម និងកិច្ចសហប្រតិបត្តិការប្រកបដោយភាពជាដៃគូកម្រិតខ្ពស់។

ឃ.កិច្ចសហប្រតិបត្តិការជាតិ-អន្តរជាតិ

កិច្ចសហប្រតិបត្តិការជាតិជាយន្តការនៃអន្តរកម្មសម្របសម្រួលកម្រិតជាតិ ដែលមានតួនាទីចាំបាច់ និងមានសារៈសំខាន់ក្នុងការលើកកម្ពស់ផែនការមេស្តីពី បរិវត្តកម្មព្រឹទ្ធសភាអេឡិចត្រូនិក ឱ្យមានដំណើរការប្រកបដោយភាពសកម្ម និងរស់រវើកតាមរយៈការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីឱ្យសកម្មភាពនីមួយៗបានដំណើរការតាមជំហាន និងតាមដំណាក់កាលនៃវឌ្ឍនភាពរបស់ជាតិក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាននេះ។ យន្តការនៃកិច្ចពិភាក្សា ការពិគ្រោះយោបល់ សិក្ខាសាលា និងកម្មវិធីផ្សេងៗ ត្រូវប្រើប្រាស់ជាប្រចាំ និងទៅតាមដំណាក់កាលនៃការអនុវត្តសកម្មភាពនៃផែនការមេនេះ ដើម្បីលើកកម្ពស់ការប្រមូលធាតុចូល និងបទពិសោធន៍ល្អៗផង ក៏ដូចជាការបង្កើតនូវប្រសិទ្ធភាព ព្រមទាំងប្រសិទ្ធផលជាអតិបរមាផង។

កិច្ចសហប្រតិបត្តិការអន្តរជាតិជាយន្តការដែលអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងព្រឹទ្ធសភាបានពូនជ្រុំ និងពង្រឹងពង្រីកចាប់តាំងពីការបង្កើតព្រឹទ្ធសភានៅឆ្នាំ១៩៩៩។ កិច្ចសហប្រតិបត្តិការអន្តរជាតិនឹងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី-ពហុភាគីទាំងក្នុងក្របខ័ណ្ឌអង្គការអន្តរសភាកម្រិតតំបន់ និងកម្រិតពិភពលោក។ កិច្ចសហប្រតិបត្តិការជារួមបានផ្តោតទៅលើផ្នែកសំខាន់ៗមួយចំនួនដូចជា កិច្ច-សហប្រតិបត្តិការកម្រិតបច្ចេកទេស និងការអភិវឌ្ឍធនធានមនុស្ស កិច្ចសហប្រតិបត្តិការនៃការផ្លាស់ប្តូរបទពិសោធន៍ និងចំណេះដឹង កិច្ចសហប្រតិបត្តិការនៃការផ្តួចផ្តើមនវានុវត្តន៍កម្រិតតំបន់និងពិភពលោក កិច្ចសហប្រតិបត្តិការ នៃការផ្លាស់ប្តូរព័ត៌មាននិងចែករំលែកដោយទូលំទូលាយព្រមទាំងកិច្ចសហប្រតិបត្តិការផ្សេងៗ ដែលមានផលប្រយោជន៍រួមគ្នា។

២.ការវាយតម្លៃ និងការតាមដានការអនុវត្តផែនការមេ

ដើម្បីធានាបាននូវវឌ្ឍនភាព ប្រសិទ្ធភាព សង្គតិភាព និងដំណោះស្រាយលើបញ្ហានានាឱ្យបានទាន់ពេលវេលាក្នុងការអនុវត្តសកម្មភាពរបស់ផែនការមេនេះ គណៈកម្មការបច្ចេកវិទ្យាព័ត៌មានព្រឹទ្ធសភាត្រូវប្រើប្រាស់នូវយន្តការចាំបាច់មួយចំនួនដូចជម្រាបខាងក្រោម៖

- បង្កើតនូវប្រព័ន្ធតាមដាន និងវាយតម្លៃការអនុវត្តសកម្មភាព ដោយកំណត់សូចនាករជាក់លាក់ ដែលអាចវាស់វែងបានប្រកបដោយលក្ខណៈប្រាកដនិយម និងមានលក្ខណៈឆ្លើយឆ្លងទៅនឹងទស្សនវិស័យរយៈពេលវែង យុទ្ធសាស្ត្រតាមដំណាក់កាលនីមួយៗ និងប្រតិបត្តិការការងាររបស់ព្រឹទ្ធសភាតាមជំហានៗ។
- ការសិក្សាស្រាវជ្រាវ និងកំណត់ប្រភពទិន្នន័យ ឬវិធីសាស្ត្រស្វែងរកទិន្នន័យ សម្រាប់សកម្មភាពនានាក្នុងផែនការមេ ដោយមានការចូលរួម និងផ្តល់យោបល់ពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីធានាថាសកម្មភាពដែលបានអនុវត្តន៍ និងត្រូវអនុវត្តន៍នាពេលខាងមុខ គ្របដណ្តប់វិសាលភាព និងតម្រូវការរបស់ភាគីពាក់ព័ន្ធជាអតិបរិមា និងគ្រប់ជ្រុងជ្រោយ។
- រៀបចំផែនការសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តជាមួយការពិពណ៌នាដោយមានរបាយការណ៍ទៀងទាត់។
- បង្កើតប្រព័ន្ធរាយការណ៍ និងទម្រង់គំរូរបាយការណ៍ប្រកបដោយលក្ខណៈងាយស្រួល និងហ្មត់ចត់សម្រាប់ជាមធ្យោបាយសម្រួលដល់ការរាយការណ៍របស់អង្គភាពអនុវត្តន៍ទទួលផល ព្រមទាំងភាគីពាក់ព័ន្ធមានភាពងាយស្រួលក្នុងការចូលរួម។

ក.ការតាមដាន

ការតាមដានការអនុវត្តសកម្មភាពនានារបស់ផែនការមេ គឺជាការពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តសកម្មភាព និងផែនការមេស្តីពីបរិវត្តកម្មអេឡិចត្រូនិករបស់ព្រឹទ្ធសភា។ ការវាយតម្លៃលទ្ធផលត្រូវឈរលើមូលដ្ឋាននូវការប្រៀបធៀបរវាងលទ្ធផលរំពឹងទុក និងផលវិជ្ជមាននៃគម្រោងនីមួយៗ ដើម្បីកំណត់នូវលទ្ធផលពិតប្រាកដ និងបញ្ហាប្រឈមនានាដែលរាំងស្ទះដល់ដំណើរការអនុវត្ត។ ដើម្បីពង្រឹងការសម្របសម្រួលដល់ការតាមដានប្រកបដោយគុណភាព គណៈកម្មការបច្ចេកវិទ្យាព័ត៌មានព្រឹទ្ធសភាអាចដាក់ចេញផែនការតាមដានការអនុវត្តសកម្មភាពឱ្យបានទៀងទាត់ និងច្បាស់លាស់តាមរយៈការបង្កើតប្រព័ន្ធរាយការណ៍ និងវិធីសាស្ត្រទំនាក់ទំនងប្រកបដោយលក្ខណៈសាមញ្ញ និងងាយស្រួល។គណៈកម្មការបច្ចេកវិទ្យាព័ត៌មានព្រឹទ្ធសភាត្រូវរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ឆមាស និងឆ្នាំ ដើម្បីពិនិត្យរបាយការណ៍បូកសរុបលើវឌ្ឍនភាពនៃការអនុវត្ត និងការដោះស្រាយបញ្ហាប្រឈមព្រមទាំងសំណូមពរផ្សេងៗ ដើម្បីធានាដល់ដំណើរការនៃការអនុវត្តសកម្មភាពឬផែនការការងារប្រកបដោយភាពរលូន និងមានប្រសិទ្ធភាព។

ខ.ការវាយតម្លៃ

យន្តការនៃការវាយតម្លៃមានសារៈសំខាន់ក្នុងការពិនិត្យប្រសិទ្ធភាព និងប្រសិទ្ធផល នៃការអនុវត្តសកម្មភាពនានា ដែលបានបញ្ចប់ថាតើវិសាលភាព និងផលវិជ្ជមានទៅលើប្រតិបត្តិការ ព្រមទាំងអត្ថប្រយោជន៍ដល់ព្រឹទ្ធសភាកម្រិតណា។ កត្តានេះគឺជាចំណុចសំខាន់ ដើម្បីធានាដល់និរន្តភាព និងធានាប្រសិទ្ធភាពក្នុងកាលៈទេសៈមួយថ្មីដែលមានការប្រែប្រួលលឿនរហ័សនៃបច្ចេកវិទ្យាថ្មីៗ។ ក្នុងអត្ថន័យនេះ គណៈកម្មការបច្ចេកវិទ្យាព័ត៌មានព្រឹទ្ធសភាត្រូវបន្តពិនិត្យឡើងវិញនូវសកម្មភាពក្នុងគម្រោងចាស់ និងថ្មី ដើម្បីធានាការកែតម្រូវ និងដោះស្រាយឱ្យ

បានទាន់ពេលវេលាតាមដំហានសមស្របនីមួយៗក្នុងបរិការណ៍ថ្មី និងប្រសើរជាងមុន។ ការវាយតម្លៃ និងកែសម្រួលត្រូវធ្វើឡើងដោយឈរលើសូចនាករប្រាកដនិយម និងមានប្រភពទិន្នន័យច្បាស់លាស់។ បន្ថែមពីនេះគណៈកម្មការបច្ចេកវិទ្យាព័ត៌មានព្រឹទ្ធសភាត្រូវកំណត់ និងការដាក់ចេញនូវផែនការវាយតម្លៃតាមរយៈវិធីសាស្ត្រនៃការសិក្សាស្វែងរកទិន្នន័យ និងប្រៀបធៀបមុននឹងធ្វើការសម្រេចដាក់ចេញនូវយុទ្ធសាស្ត្រថ្មីៗព្រមទាំងសកម្មភាពកែតម្រូវផ្សេងៗ។

៣.ឱកាស និងបញ្ហាប្រឈម

ការអនុវត្តសកម្មភាព និងគោលដៅនៃផែនការមេខាងលើតាមដំហាននីមួយៗ នឹងរំលេចមកនូវឱកាស និងបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននឹងបង្កើតការទាក់ទាញឱ្យប្រជាពលរដ្ឋ និងមជ្ឈដ្ឋានសាធារណៈមាន ទំនាក់ទំនងជាមួយនឹងព្រឹទ្ធសភាកាន់តែប្រសើរឡើង និងស្និទ្ធស្នាល
- ការប្រើប្រាស់បច្ចេកទេសវិទ្យាព័ត៌មាននឹងបង្កើនចំណាប់អារម្មណ៍ពីស្ត្រី យុវជន កុមារ និងក្រុមមនុស្សផ្សេងៗនៅក្នុងសង្គម ដើម្បីទំនាក់ទំនងជាមួយនឹងព្រឹទ្ធសភា ប្រកបដោយបរិយាបន្ន និងប្រសិទ្ធភាព
- ការប្រើប្រាស់ឧត្តមភាព និងសក្តានុពលនៃបច្ចេកវិទ្យាព័ត៌មាននាំឱ្យបង្កើនប្រសិទ្ធភាពក្នុងការចូលរួម ព្រមទាំងបំពេញនូវកង្វះខាត ដែលរាំងដល់ព្រឹទ្ធសភា និងប្រជាពលរដ្ឋក្នុងការពន្លឿនខឿននីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ
- បច្ចេកវិទ្យាព័ត៌មាននឹងចូលរួមដោយផ្ទាល់ ឬប្រយោលក្នុងការផ្លាស់ប្តូរនូវទស្សនៈដោយសន្សឹមៗដល់សមាជិកព្រឹទ្ធសភា ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធ ដើម្បីចូលរួមពង្រឹងនីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យដោយមនសិការ និងភាពវិជ្ជមាន
- ការបញ្ចូលបច្ចេកវិទ្យាព័ត៌មាននឹងបង្កើតឱ្យមានភាពប្រសើរឡើងនូវទស្សនៈការប្រកួតប្រជែងដោយវិជ្ជមានក្នុងរូបភាពជាជើងឯកសភា ឬសភាឆ្នើម
- ប្រសិទ្ធភាពនិងប្រសិទ្ធផលនៃបច្ចេកវិទ្យាព័ត៌មានអាចនឹងបង្កើតលទ្ធផលខុសគ្នាទៅតាមលក្ខណៈសម្បត្តិ លក្ខខណ្ឌ និងការទទួលយករបស់សមាជិកសភា ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធផ្សេងៗ

៤. លទ្ធផលរំពឹងទុក

ដើម្បីឱ្យសកម្មភាព និងគោលដៅនៃផែនការមេអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងប្រសិទ្ធផលខ្ពស់ លទ្ធផលរំពឹងទុកអាចត្រូវបានកំណត់ដូចខាងក្រោម៖

- ទំនាក់ទំនងសាធារណៈ ព័ត៌មាន និងបច្ចេកវិទ្យាព័ត៌មាន រវាងព្រឹទ្ធសភា និង មជ្ឈដ្ឋានសាធារណៈនឹងមានដំណើរការប្រកបដោយភាពរស់រវើក ប្រសិទ្ធភាព និងភាពប្រសើរឡើង ហើយនាំមកនូវកំណើនប្រជាពលរដ្ឋកាន់តែច្រើនជាងមុនដែលមានការប្រាស្រ័យឆ្លើយឆ្លងជាមួយនឹងព្រឹទ្ធសភា

- តាមរយៈការទាញយកសក្ដានុពល និងឧត្ដមភាពនៃបច្ចេកវិទ្យាព័ត៌មាននឹងបង្កើតមធ្យោបាយ ហើយនឹងនាំមកនូវវិធីសាស្ដ្រទំនាក់ទំនង និងការបំពេញការងាររបស់ព្រឹទ្ធសភាប្រកបដោយប្រសិទ្ធផលខ្ពស់តាមរយៈបណ្ដាញច្រើនជាងមុន
- បរិមាណ និងគុណភាពនៃអ្នកបោះឆ្នោតនឹងបន្ដកើនឡើង តាមរយៈការចូលរួមពីម្ចាស់ឆ្នោតរបស់ព្រឹទ្ធសភា(បោះឆ្នោតអសកល) និងការបោះឆ្នោតជាតិ(សកល)
- មតិអវិជ្ជមានចំពោះព្រឹទ្ធសភានឹងត្រូវបានកាត់បន្ថយ ទន្ទឹមនឹងមតិគាំទ្រនឹងត្រូវបានពង្រឹងពង្រីក និងរឹងមាំបន្ថែមទៀត
- ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងកិច្ចការសភាអាចជាផ្នែកមួយនៃការអប់រំសម្រាប់កុមារ និងយុវជន ដែលជាទំពាំងស្នងឬស្សីរបស់ជាតិ ហើយនាំមកនូវកាលានុវត្តភាពសម្រាប់ការពង្រឹងខឿនសេដ្ឋកិច្ច និងសង្គមជាតិ ជាពិសេសវប្បធម៌សភា វប្បធម៌នីតិរដ្ឋ វប្បធម៌ប្រជាធិតេយ្យ និងវប្បធម៌សន្តិភាព

៥.ទីតាំង (Focus Area)

ដើម្បីអនុវត្តនូវសកម្មភាព និងគោលដៅប្រកបដោយភាពប្រាកដនិយម និងឆ្លើយតបជាមួយទស្សនវិស័យឆ្ពោះទៅជាសភាទំនើប ទីតាំងចាំបាច់មួយចំនួនត្រូវបានកំណត់ដូចខាងក្រោម៖

- ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានដែលមានភាពរឹងមាំ និងទំនុកចិត្តខ្ពស់ នាំឱ្យមានការទាក់ទាញនូវការប្រើប្រាស់ និងការទទួលយកពីសំណាក់ប្រជាពលរដ្ឋ ព្រមទាំងអ្នកប្រើប្រាស់
- សេវាកម្ម និងឧបករណ៍ឌីជីថលក្នុងមុខងារស្នូលទាំងបី ដែលមានភាពងាយស្រួល សាមញ្ញ ប្រកបដោយវិជ្ជាជីវៈសភា និងបច្ចេកទេសព័ត៌មាន នាំមកនូវការបង្កើនបរិយាកាសទទួលយក និងកាលានុវត្តភាពប្រសើរឡើង
- ផែនការសកម្មភាពដែលមានការដឹកនាំត្រឹមត្រូវ និងច្បាស់លាស់ នាំមកនូវសកម្មភាពដែលរស់រវើក និងទាក់ទាញឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធ
- ការកសាង និងពង្រឹងទំនាក់ទំនងសាធារណៈជាស្នូលសម្រាប់ដំណើរការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានសម្រាប់ព្រឹទ្ធសភា
- កិច្ចសហការនិងសហប្រតិបត្តិការប្រកបដោយភាតរភាពជាកត្តាចាំបាច់ក្នុងការពង្រឹងពង្រីកឧត្ដមភាពទៅលើការអនុវត្តសកម្មភាព និងគោលដៅក្នុងផែនការមេនេះ

៦. អតិថិជនគោលដៅ (Target Audiences)

ដើម្បីឱ្យផែនការមេឆ្លើយតបបានត្រឹមត្រូវទៅលើសេចក្ដីត្រូវការរួមរបស់ស្ថាប័ន និងអតិថិជន អតិថិជនសំខាន់ៗត្រូវបានកំណត់ដូចខាងក្រោម៖

- <u>**អតិថិជនស្នូល:**</u> **ព្រឹទ្ធសភា** ជាអ្នកដែលតំណាងឱ្យភាពជម្មានរូប និងសមូហភាព។ **សមាជិកព្រឹទ្ធសភា** និងមន្ត្រីអគ្គលេខាធិការដ្ឋាន ជាអតិថិជនផ្ទាល់ (Immediate Customer) ក្នុងការចូលរួម និងប្រើប្រាស់ដោយផ្ទាល់ ហើយក៏ជាអ្នកដែលទទួលផលបឋម។ បន្ថែមពីនេះ **គណៈកម្មាធិការអេចិន្ត្រៃយ៍ព្រឹទ្ធសភា**ជារចនាសម្ព័ន្ធនយោបាយដែលជាតួអង្គដ៏មានសារៈសំខាន់ ដើម្បីកំណត់ផែនការសកម្មភាព និងទិសដៅការងាររបស់ព្រឹទ្ធសភាសម្រាប់នីតិកាលនីមួយៗ។
- <u>**អតិថិជនសំខាន់:**</u> **ក្រុមប្រឹក្សាឃុំ-សង្កាត់** ជាម្ចាស់ឆ្នោតរបស់សមាជិកព្រឹទ្ធសភា និងតួអង្គសកម្មក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដើម្បីធ្វើអន្តរកម្មទំនាក់ទំនងជាមួយនឹងសមាជិកព្រឹទ្ធសភា និងព្រឹទ្ធសភា។ **ប្រជាពលរដ្ឋ** ជាអ្នកចូលរួមប្រើប្រាស់ផ្ទាល់ដែលឆ្លើយតបនឹងសេវាកម្មរវាងប្រជាពលរដ្ឋ និងព្រឹទ្ធសភា។ **ស្ត្រី យុវជន និងកុមារ** ជាអតិថិជនគោលដៅដែលត្រូវពង្រឹង និងពង្រីកទំនាក់ទំនងឱ្យកាន់តែមានភាពជិតដិត។
- <u>**អ្នកចូលរួម:**</u> **អង្គការក្រៅរដ្ឋាភិបាល** ជាអតិថិជន និងជាដៃគូសហការក្នុងការចូលរួមបំពេញបន្ថែមក្នុងការអនុវត្តសកម្មភាព និងគោលដៅ ប្រកបដោយប្រសិទ្ធភាព និងជាតុចូលគ្រប់គ្រាន់។ **ដៃគូជាតិ-អន្តរជាតិ** ជាដៃគូសហការប្រកបដោយភាតរភាព ដែលចូលរួមសហការ និងបំពេញបន្ថែមក្នុងដំណើរការនៃការអនុវត្តសកម្មភាព និងគោលដៅនានាក្នុងការផែនការមេនេះ។ **វិស័យឯកជន** ជាដៃគូរួមសហការក្នុងការបំពេញបន្ថែមសំខាន់ទៅលើការងារបច្ចេកទេសបច្ចេកវិទ្យាព័ត៌មាន រួមមាន ក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មាន អ្នកផ្គត់ផ្គង់សេវាអ៊ីនធឺណិត អ្នកបច្ចេកទេសអភិវឌ្ឍន៍សុហ្វែរ អ្នកជំនាញហេដ្ឋារចនាសម្ព័ន្ធ អ្នកស្រាវជ្រាវ និងបញ្ញវន្ត។ បន្ថែមពីនេះ **ប្រព័ន្ធផ្សព្វផ្សាយ** (Media) គឺជាអ្នកដែលចូលរួមផ្សព្វផ្សាយ និងចូលរួមពង្រីកវិសាលភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងការងារទំនាក់ទំនងសាធារណៈរបស់ព្រឹទ្ធសភាអោយមានលក្ខណៈទូលំទូលាយ ព្រមទាំងជ្រួតជ្រាបដល់ប្រជាពលរដ្ឋ
- <u>**អ្នកអនុវត្ត:**</u> អង្គភាពបច្ចេកទេស (នាយកដ្ឋានព័ត៌មានវិទ្យា) អង្គភាពចំណុះអគ្គលេខាធិការដ្ឋាន មន្ត្រីបច្ចេកទេស និងមន្ត្រីប្រើប្រាស់ (End User) ជាក្រុមអតិថិជនសកម្ម ឬក្រុមការងារអនុវត្តន៍សកម្មភាព និងគោលដៅ ដើម្បីបង្កើតលទ្ធផល និងសម្រេចគោលដៅតាមការគ្រោងទុករបស់ផែនការមេនេះ ។

៧. បណ្ដាញ និងផលិតផល

ដើម្បីកំណត់សកម្មភាព និងគោលដៅឲ្យបានត្រឹមត្រូវឆ្លើយតបនឹងអតិថិជន បណ្ដាញ និងផលិតផលរបស់ព្រឹទ្ធសភាត្រូវបានកំណត់ក្នុងតារាងខាងក្រោម៖

អតិថិជន	បណ្ដាញ ឬមធ្យោបាយឌីជីថល	ឧទាហរណ៍ទាក់ទងនឹងផលិតផលរបស់ព្រឹទ្ធសភា ដែលពួកគេចាប់អារម្មណ៍
១.អតិថិជនស្នូល	• គេហទំព័រព្រឹទ្ធសភា • សុហ្វែរទិន្នន័យច្បាប់	• ឯកសារច្បាប់ឌីជីថល • ព័ត៌មានព្រឹទ្ធសភា

	• សុហ្វែរបណ្ណាល័យអេឡិចត្រូនិក • ទិន្នន័យឯកសារស្រាវជ្រាវ • សាលឌីជីថល(Paperless System) • សុហ្វែរស្ថិតិទិន្នន័យថវិកាជាតិ • សិក្ខាសាលា និងកម្មវិធីកិច្ចពិភាក្សាពិគ្រោះយោបល់	• ឯកសារបោះពុម្ព • ឯកសារស្រាវជ្រាវ • បច្ចុប្បន្នភាពនៃច្បាប់ • របាយការណ៍ស្តីពីវឌ្ឍនភាពនៃព្រឹទ្ធសភាអេឡិចត្រូនិក
២. អតិថិជនសំខាន់	• គេហទំព័រ អ៊ីម៉ែល បណ្តាញសង្គម • សុហ្វែរទទួលពាក្យបណ្តឹង • សុហ្វែរពិភាក្សាពីចម្ងាយ • វិទ្យុ និងទូរទស្សន៍អនឡាញ • សុហ្វែរស្ថិតិទិន្នន័យថវិកាជាតិ	• ពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ • ព័ត៌មាន និងយោបល់ផ្សេងៗ • ព័ត៌មាន វីដេអូ និងសំឡេង ការងារសកម្មភាពរបស់ព្រឹទ្ធសភា
៣.អ្នកចូលរួម	• គេហទំព័រ • ផែនការ និងសកម្មភាព • សុហ្វែរទទួលពាក្យបណ្តឹង • សុហ្វែរពិភាក្សាពីចម្ងាយ • អ៊ីម៉ែល (E-mail) • សិក្ខាសាលា	• ផែនការប្រតិបត្តិ កាលវិភាគការងារ (Log Frame) និងកិច្ចការងារផ្សេងៗរបស់ព្រឹទ្ធសភា • គម្រោងការងារ • ថ្នាលឌីជីថល (Camdex) • បទពិសោធន៍ និងការសិក្សា (Lesson-learned)
៤. អ្នកអនុវត្ត	• សិក្ខាសាលា ឬកិច្ចពិភាក្សា • ផែនការមេស្តីពីបរិវត្តកម្មព្រឹទ្ធសភាអេឡិចត្រូនិក • គេហទំព័រ • បណ្តាញសង្គម • សិក្ខាសាលា	• គម្រោងការងារ សកម្មភាព និងគោលដៅ • វប្បធម៌ឌីជីថល • បទពិសោធន៍របស់សភានានា • ការសិក្សារបស់អន្តរសភា (IPU) • ថ្នាលឌីជីថលបែបចែករំលែក

៨. ធនធានមនុស្ស និងហិរញ្ញវត្ថុ

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជាសេនាធិការរដ្ឋបាល និងបច្ចេកទេសសម្រាប់ព្រឹទ្ធសភា ហើយបានចាត់តាំងឱ្យនាយកដ្ឋានព័ត៌មានវិទ្យានៃអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ ជាអង្គភាពបច្ចេកទេសដែលមានធនធានមនុស្សសម្រាប់អនុវត្តសកម្មភាព និងគោលដៅក្នុងផែនការមេនេះ។ ក្នុងនោះ ការិយាល័យជំនាញ និងអ្នកបច្ចេកទេស បានត្រូវចាត់តាំងឱ្យទទួលខុសត្រូវអនុវត្តន៍ការងារបច្ចេកទេស និងការសិក្សាស្រាវជ្រាវ ដោយមានការសហការជាមួយអតិថិជនផ្ទាល់ ឬប្រយោល ព្រមទាំងភាគីពាក់ព័ន្ធផ្សេងៗ ។ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានកំណត់ធនធានហិរញ្ញវត្ថុដោយគ្រោងថវិកាបរិមាណ២០០០លានរៀល(ពីរពាន់លានរៀល)សម្រាប់ការអនុវត្តសកម្មភាពឆ្លើយតបនឹងការកសាងហេដ្ឋារចនាសម្ព័ន្ធ និងសម្រាប់ការបំពាក់ឧបករណ៍ និងបរិក្ខារអេឡិចត្រូនិកសម្រាប់ការប្រើប្រាស់ក្នុងឆ្នាំនីមួយៗ តាមរយៈថវិកាតាមកម្មវិធី ដើម្បីគាំទ្រដល់ដំណើរការអនុវត្តសកម្មភាពឆ្លើយតបនឹង

ទស្សនវិស័យឆ្ពោះទៅជាសភាទំនើប។ ជាសរុបក្នុងការអនុវត្តសកម្មភាពក្នុងរយៈពេល (២០២២-២០៣០) ថវិកាសរុបដែលគ្រោងនឹងចំណាយសម្រាប់ប្រើប្រាស់មានប្រមាណជា ១៦.០០០លានរៀល (ដប់ប្រាំមួយពាន់លានរៀល) និងប្រហាក់ប្រហែលជា៤លានដុល្លារសហរដ្ឋអាមេរិកសម្រាប់អនុវត្តន៍ផែនការមេនេះ។ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសូមស្វាគមន៍ចំពោះការបន្តការគាំទ្រពី ដៃគូជាតិ និងអន្តរជាតិ ក្នុងការចូលរួមវិភាគទាន និងកិច្ចសហប្រតិបត្តិការដ៏ថ្លៃថ្លារបស់ដៃគូ ដើម្បីជម្រុញដល់ដំណើរការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភា។

VIII.ការគ្រប់គ្រងហានិភ័យ

១-ហានិភ័យពាក់ព័ន្ធនឹងរបៀបរបបការងារសភា

ក្នុងការសម្រេចផែនការមេនេះ ឱ្យបានទទួលជោគជ័យស្របតាមការគ្រោងទុកចាំបាច់ត្រូវមានការចូលរួមអនុវត្តន៍ដោយសកម្ម និងភាពវិជ្ជមានពីសំណាក់គ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ភាគីពាក់ព័ន្ធទាំងកម្រិតនយោបាយ និងកម្រិតបច្ចេកទេសត្រូវរួមគ្នាជំរុញ និងលើកកម្ពស់ឱ្យមានការប្រើប្រាស់ព្រមទាំងការអនុវត្តបច្ចេកវិទ្យាព័ត៌មានសំដៅសម្រេចនូវចក្ខុវិស័យ និងទស្សនវិស័យរបស់ព្រឹទ្ធសភា។ ព្រឹទ្ធសភាត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាមានអាណត្តិរយៈពេលប្រាំមួយឆ្នាំ។ ក្នុងន័យនេះ គ្រប់កាលៈទេសៈ និងគ្រប់នីតិកាល បច្ចេកវិទ្យាព័ត៌មានត្រូវរៀបចំប្រកបដោយស្មារតីទទួលខុសត្រូវ និងម្ចាស់ការ ដើម្បីធានានូវប្រក្រតីភាពស្ថាប័ន និងការផ្តល់សេវាជូនសមាជិកព្រឹទ្ធសភាប្រកបដោយភាពរលូន និងបត់បែនខ្ពស់។ គម្រោងបច្ចេកវិទ្យាព័ត៌មានត្រូវបង្កើតឡើងឈរលើមូលដ្ឋាននៃភាពបត់បែន និងការសម្របសម្រួល ដើម្បីធានាបានថាសេវាកម្ម និងគម្រោងបច្ចេកទេសព័ត៌មានបានគ្របដណ្តប់លើសេចក្តីត្រូវការរួមរបស់ស្ថាប័នស្របតាមតម្រូវការអតិថិជន និងគ្រប់កាលៈទេសៈ។

លក្ខណៈសម្បត្តិ ឬគោលបំណងចម្បងនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសំដៅលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពសម្រាប់ស្ថាប័នរបស់ព្រឹទ្ធសភា ជាពិសេសអ្នកប្រើប្រាស់ (ផ្ទាល់-ប្រយោល)។ ចំពោះរបៀបរបបការងារមានលក្ខណៈប្រពៃណី និងទម្លាប់ចាស់ត្រូវជំនួសដោយរបៀបថ្មី និងទម្រង់ថ្មី ដែលជាកត្តាបង្កការលំបាកដល់អ្នកប្រើប្រាស់ក្នុងដំណាក់កាលដំបូងៗ ឧទាហរណ៍ ១.ការប្រើប្រាស់សារឌីជីថលជំនួសដោយការសរសេរលិខិតផ្ទាល់ និងបោះពុម្ពឯកសារជាក្រដាស ២.ការប្រជុំអនឡាញជំនួសដោយការប្រជុំផ្ទាល់ ៣.ការងារធ្វើដោយដៃជំនួសដោយការប្រើប្រាស់ឧបករណ៍ឌីជីថល និងបច្ចេកវិទ្យាព័ត៌មាន..។ល។ ដើម្បីទប់ស្កាត់ និងកែសម្រួលនូវហានិភ័យនេះឱ្យក្លាយជាកាលានុវត្តភាព ចាំបាច់ត្រូវពង្រីកការបណ្តុះបណ្តាលដល់មន្ត្រីគ្រប់ជាន់ថ្នាក់ និងសមាជិកព្រឹទ្ធសភា ព្រមទាំងអតិថិជន (អ្នកប្រើប្រាស់ផ្ទាល់-ប្រយោល) ឱ្យទទួលបាននូវចំណេះដឹង ចំណេះធ្វើប្រកបដោយភាពទូលំទូលាយ និងជាប្រចាំតាមរយៈវិធីសាស្ត្រអប់រំជាលំដាប់លំដោយ។

២-ហានិភ័យពាក់ព័ន្ធនឹងការប្រើប្រាស់អ្នកផ្គត់ផ្គង់ខាងក្រៅ

ការប្រើប្រាស់អ្នកផ្គត់ផ្គង់ខាងក្រៅនឹងផ្តល់អត្ថប្រយោជន៍ និងរួមចំណែកយ៉ាងច្រើនដល់ការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានមនុស្ស ថវិកា ឧបករណ៍ បច្ចេកទេស ទីកន្លែង និងមធ្យោបាយ។ តែទោះបីជាយ៉ាងដូច្នេះក្តី ការប្រើប្រាស់ធនធានអ្នកផ្គត់ផ្គង់ខាងក្រៅដោយខ្វះខាតវិធីសាស្ត្រគ្រប់គ្រងដូចជា វិធីសាស្ត្រ យន្តការ ការប្រាស្រ័យ

ឆ្លើយឆ្លង និងការកំណត់ធនធានឱ្យបានត្រឹមត្រូវ នោះជាកត្តានាំមកនូវផលអវិជ្ជមាន ដែលនឹងបង្កការរាំងស្ទះ និងការរអាក់រអួលក្នុងការអនុវត្តសកម្មភាពមួយចំនួនផង ហើយវាថែមទាំងនឹងបង្កការរំខានទៅដល់នូវផលិតកម្ម ផលិតផល និងសេវាកម្មបច្ចេកវិទ្យាព័ត៌មានដែលមានលក្ខណៈចាំបាច់សម្រាប់អតិថិជន។ ដូចនេះ សកម្មភាពនានាក្នុងផែនការមេត្រូវធ្វើឡើងដោយប្រើប្រាស់វិធីសាស្ត្រ និងនិយាមដែលមានស្តង់ដារត្រឹមត្រូវ ព្រមទាំងមានលក្ខណៈសមស្របទៅនឹងកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ជាពិសេសស្តង់ដារនិងនិយាមបច្ចេកវិទ្យាព័ត៌មាន ការងាររដ្ឋបាល ថវិកា ការងារលទ្ធកម្ម។ គណៈកម្មការបច្ចេកវិទ្យាព័ត៌មាន ត្រូវដឹកនាំអង្គភាពជំនាញបច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភាឱ្យខិតខំកសាងនូវបទដ្ឋានបច្ចេកទេស និងគោលនយោបាយបច្ចេកវិទ្យាព័ត៌មានដែលមានលក្ខណៈសមស្របទៅនឹងបរិយាកាសការងាររបស់សភាដោយប្រើប្រាស់នូវបទដ្ឋានគតិយុត្ត កិច្ចសន្យាការងារផ្គត់ផ្គង់បច្ចេកទេស និងមូលដ្ឋានបច្ចេកទេសទាក់ទងនឹងប្រព័ន្ធថ្នាលឌីជីថល កូដនីយកម្ម កម្មវិធី និងសេវាកម្មបច្ចេកវិទ្យាព័ត៌មានតាមបរិបទនៃវឌ្ឍនភាពបច្ចេកវិទ្យាព័ត៌មានរបស់ជាតិ-អន្តរជាតិ។

៣-ហានិភ័យពាក់ព័ន្ធនឹងធនធានមនុស្ស និងហិរញ្ញវត្ថុ

ធនធានមនុស្ស និងហិរញ្ញវត្ថុជាកត្តាដ៏សំខាន់ក្នុងការសម្រេចបានជោគជ័យនៃការអនុវត្តសកម្មភាពនានារបស់ផែនការមេនេះ។ ហានិភ័យធំៗទាក់ទងនឹងធនធានមនុស្ស ១. ខ្វះធនធានមនុស្សដែលមានជំនាញឯកទេស មានភាពសកម្ម មានឆន្ទៈ និងស្មារតីទទួលខុសត្រូវខ្ពស់ ២. អត្រានៃការចាកចេញ និងការផ្លាស់ប្តូររបស់មន្ត្រីបច្ចេកទេសមានកម្រិតមួយគួរកត់សម្គាល់ដោយកត្តាចូលនិវត្តន៍ មរណភាព និងហេតុផលផ្ទាល់ខ្លួននានា។ ដោយឡែកហានិភ័យទៅលើហិរញ្ញវត្ថុមានកត្តាពីរធំៗ ១. អប្បបរមានៃថវិកាសម្រាប់ការវិនិយោគបច្ចេកវិទ្យាព័ត៌មានក្នុងការដោះស្រាយបញ្ហាបច្ចេកទេសបន្ទាន់ៗ និងមានហានិភ័យខ្ពស់ដូចជា ការងារសន្តិសុខសុវត្ថិភាព និងគុណភាព នៃសេវាកម្មបច្ចេកវិទ្យាព័ត៌មាន។ ២. ផលវិនិយោគ (ROI) និងប្រសិទ្ធភាពនៃសកម្មភាពនានារបស់បច្ចេកវិទ្យាព័ត៌មាន នៅមានភាពមិនច្បាស់លាស់។ ការគ្រប់គ្រងធនធានមនុស្សត្រូវមានគោលនយោបាយគ្រប់គ្រងកាន់តែល្អប្រសើរដោយផ្តោតការកសាងស្មារតី និងជំនាញប្រកបដោយការទទួលខុសត្រូវ ព្រមទាំងម្ចាស់ការខ្ពស់ ជាពិសេសការកសាង នូវមូលដ្ឋាន និងលក្ខណៈស្តង់ដារវិនិច្ឆ័យទៅលើលទ្ធផលរបស់មន្ត្រីម្នាក់ៗ ដែលមានស្នាដៃការងារ និងចំណេះដឹង ចំណេះធ្វើពិតប្រាកដ។ បន្ថែមពីនេះ រាល់សេចក្តីត្រូវការថ្មីៗដែលមានលក្ខណៈហួសពីលទ្ធភាព និងសមត្ថភាពធនធានមនុស្សរបស់ស្ថាប័ន ត្រូវបង្វែរឬប្រតិភូកម្មការងារនេះតាមរយៈកិច្ចសហប្រតិបត្តិការជាមួយនឹងដៃគូជាតិ-អន្តរជាតិទាំងវិស័យឯកជន-រដ្ឋ ដោយភ្ជាប់នឹងលក្ខខណ្ឌកិច្ចសហប្រតិបត្តិការ និងកិច្ចសន្យាការងារ។ ដើម្បីជៀសវាងនៃការប្រឈមហានិភ័យថវិកា គម្រោងបច្ចេកវិទ្យាព័ត៌មាន ឬសកម្មភាពនៃផែនការមេនេះដែលបានកំណត់ទុកជាមុនត្រូវមានការតាមដាន និងវាយតម្លៃជាប្រចាំ ហើយក្នុងកាលៈទេសៈចាំបាច់ សកម្មភាពទាំងអស់នោះត្រូវកំណត់រៀបចំអាទិភាពសកម្មភាពឡើងវិញ ប្រកបដោយភាពប្រាកដនិយមតាមរយៈការពិគ្រោះយោបល់ និងធ្វើបច្ចុប្បន្នភាពឱ្យបានត្រឹមត្រូវ ដើម្បីប្រមូលជាតុចូលឱ្យបានគ្រប់គ្រាន់។ ក្នុងរយៈពេលបីឆ្នាំម្តង គណៈកម្មការបច្ចេកវិទ្យាព័ត៌មានរបស់ព្រឹទ្ធសភា ត្រូវធ្វើបច្ចុប្បន្នភាព និងកំណត់រៀបចំធនធាន(ជាតុចូល)ដែលសមស្របនឹងវឌ្ឍនភាព និងផលអវិជ្ជមានផ្សេងៗសម្រាប់ជាមធ្យោបាយគន្លឹះសម្រាប់ការកែលម្អ។ ជាមួយគ្នានេះ នៅពេលមានហានិភ័យថវិកាសកម្មភាព ឬគម្រោងបច្ចេកវិទ្យាព័ត៌មានត្រូវប្រើប្រាស់តាមរបៀបធនធានតិចសកម្មភាពច្រើន ជាពិសេសការប្រើប្រាស់

នូវកិច្ចសហប្រតិបត្តិការទាំងចាស់-ថ្មី ដែលត្រូវជំនួសមកប្រភពធនធាន(ជាតុចូល) ដែលអន់ខ្សោយក្នុងថេរវេលាមួយ(គ្រាចាំបាច់ ឬគ្រាអាសន្នថវិកា)។

៤-ហានិភ័យពាក់ព័ន្ធនឹងការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាព័ត៌មាន

ការរីកចម្រើននៃបច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាស្វ័យប្រវត្តិបានបន្តរីកចម្រើនឥតឈប់ឈរ ដែលបានបង្កការគំរាមកំហែងយ៉ាងច្រើនដល់បញ្ហាសន្តិសុខ និងគុណភាពនៃការផ្តល់សេវាបច្ចេកវិទ្យាព័ត៌មានប្រកបដោយភាពជឿជាក់ និងទំនុកចិត្តខ្ពស់។ ដើម្បីកាត់បន្ថយនូវហានិភ័យនេះ ផែនការមេនេះត្រូវមានការរៀបចំផែនការសកម្មភាព និងធនធានមនុស្សឱ្យបានសមស្របប្រកបដោយភាពច្បាស់លាស់ និងល្អិតល្អន់តាមរយៈការវិភាគមួយប្រកបដោយបច្ចេកទេសស្របតាមនិន្នាការបច្ចុប្បន្ន-អនាគតនៃបច្ចេកវិទ្យាព័ត៌មាន ជាពិសេសនិន្នាការអន្តរជាតិនៃវឌ្ឍនភាពរបស់បច្ចេកវិទ្យាព័ត៌មានសម្រាប់សភា និងតម្រូវការរបស់ប្រជាពលរដ្ឋ។ កិច្ចសហប្រតិបត្តិការជាតិ-អន្តរជាតិក្រោមរូបភាពនៃកិច្ចពិភាក្សា ការពិគ្រោះយោបល់ ទស្សនកិច្ច វេទិកា សិក្ខាសាលា និងកម្មវិធីផ្សេងៗត្រូវប្រើប្រាស់ក្នុងរង្វង់ជាមួយដៃគូជាតិ-អន្តរជាតិ ដើម្បីចែករំលែក និងរៀនសូត្រពីគ្នាទៅវិញទៅមកប្រកបដោយភាតរភាព និងភាពជាដៃគូកម្រិតខ្ពស់ក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន និងកិច្ចការសភា។

៥-ហានិភ័យពាក់ព័ន្ធនឹងសន្តិសុខបច្ចេកវិទ្យាព័ត៌មាន

នៅក្នុងដំណើរការនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននាពេលបច្ចុប្បន្ន ការធានាសុវត្ថិភាពព័ត៌មាន និងភាពឯកជននៃព័ត៌មានរបស់អ្នកប្រើប្រាស់ គឺជាកត្តាមួយដែលមានសារៈសំខាន់ និងចាំបាច់ក្នុងការលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន។ ហានិភ័យមួយចំនួនតែងតែកើតមានឡើងដូចជា ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត ការជ្រៀតជ្រែកប្រព័ន្ធឌីជីថលរបស់ស្ថាប័នសាធារណៈ និងឯកជន ភាពឯករាជ្យនៃព័ត៌មានរបស់ស្ថាប័នសភា ការបាត់បង់ និងលេចធ្លាយនៃព័ត៌មានដែលមានលក្ខណៈសម្ងាត់ និងអនាមិក ការកើនឡើងនៃព័ត៌មានមិនពិត (Fake News)។ ក្នុងន័យនេះ ផែនការមេស្តីពីបរិវត្តកម្មព្រឹទ្ធសភាអេឡិចត្រូនិកត្រូវមានការរៀបចំធ្វើបុរេសកម្មភាពដោយផ្តោតលើការកាត់បន្ថយហានិភ័យសន្តិសុខព័ត៌មានវិទ្យា តាមអាទិភាព និងសមស្របនឹងសមត្ថភាពលទ្ធភាពរបស់ស្ថាប័ន ព្រមទាំងត្រូវយកចិត្តទុកដាក់ផ្តោតនូវការបង្កើតកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ-អន្តរជាតិ ក្រោមកិច្ចសហ-ប្រតិបត្តិការការងារសន្តិសុខព័ត៌មានវិទ្យា ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មអន្តរជាតិអ៊ីនធឺណិត ការពារលំហអ៊ីនធឺណិត ព្រមទាំងចូលរួមកាត់បន្ថយនូវហានិភ័យសន្តិសុខ ជាអតិបរមាប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពជាសមូហភាព។

៦-ហានិភ័យពាក់ព័ន្ធនឹងប្រធានសក្តិ

ក្នុងការកសាងនូវផែនការមួយដែលមានរយៈពេលវែង ការគិតគូរទៅលើហានិភ័យនៃប្រធានសក្តិមានសារៈសំខាន់ណាស់ ដោយសារកត្តាភូមិសាស្ត្រនយោបាយ សន្តិសុខនយោបាយ សេដ្ឋកិច្ច ទំនាក់ទំនងអន្តរជាតិ កត្តាគ្រោះធម្មជាតិ គ្រោះមហន្តរាយសុខាភិបាលសាធារណៈ។ ជាក់ស្តែងអំពីការរីករាលដាលនៃជំងឺកូវីដ ១៩ ដែល

ជាឧទាហរណ៍មួយយ៉ាងច្បាស់បានកើតមានឡើង។ ការមិនទាន់បានត្រៀមលក្ខណៈ និងការរៀបចំបុរេសកម្មភាពជាមុន ដែលបានបង្កគ្រោះមហន្តរាយ និងការរាំងស្ទះដំណើរការដល់ពិភពលោក និងកម្ពុជាផងដែរ ហើយព្រឹទ្ធសភាក៏បានជួបនូវបញ្ហាមួយចំនួនពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការការងារទាក់ទងនឹងមុខងារនីតិកម្ម មុខងារតំណាង និងមុខងារតាមដានការអនុវត្តច្បាប់ ផងដែរ។

